# អគ្គិសនីកម្ពុជា
## នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

# របាយការណ៍
## ស្តីពី
## ការរុញ្ញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ
## សម្រាប់ឆ្នាំ២០២០










www.ref.gov.kh

admin@ref.gov.kh

រៀបចំដោយនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ២០២១

## សារពី
## រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី អគ្គនាយកអគ្គិសនីកម្ពុជា



យើងខ្ញុំមានមោទនភាព សូមបង្ហាញជូននូវរបាយការណ៍ប្រចាំឆ្នាំ២០២០ ដែលនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទនៃអគ្គិសនីកម្ពុជា (បន្ទាប់ពីនេះទៅហៅកាត់ថា "ម.អ.ជ.") ទទួលបាន ក្នុងការរុញច្រានផ្លែផ្កាពីការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ម.អ.ជ. បានបង្កើតឡើង ដើម្បីជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ សំដៅធ្វើយ៉ាងណាឲ្យប្រជាពលរដ្ឋនៅជនបទក្នុងព្រះរាជាណាចក្រកម្ពុជាទទួលបានអគ្គិសនីប្រើប្រាស់គ្រប់គ្នា។

ក្នុងឆ្នាំ២០២០ អគ្គិសនីកម្ពុជាបានផ្តល់ថវិកាជំនួយចំនួន ៣៧៦ ពាន់លានរៀល ដល់ ម.អ.ជ. សម្រាប់អនុវត្តន៍កម្មវិធីរុញច្រានផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។

ថវិកាជំនួយនេះ ម.អ.ជ. បានយកទៅប្រើប្រាស់ជាប្រយោជន៍ដល់គ្រួសារនៅជនបទទូទាំងព្រះរាជាណាចក្រកម្ពុជា តាមរយៈការអនុវត្តកម្មវិធីចំនួន៧ រួមមាន៖

១. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ៖ គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យពួកគាត់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយការផ្តល់ប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ឲ្យគ្រួសារជនបទខ្ចីយកទៅបង់ថ្លៃភ្ជាប់ចរន្ត ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និងចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

២. កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ៖ គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទនៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់ តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។ ម.អ.ជ. ផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ សម្រាប់ប្រព័ន្ធមានអានុភាព ៨០ វ៉ាត់ និងចំនួន ២០០ ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ សម្រាប់ប្រព័ន្ធមានអានុភាព ២០០ វ៉ាត់ និងប្រព័ន្ធមានអានុភាព ៣២៥ វ៉ាត់ មានថ្មផ្ទុកថាមពលអគ្គិសនីចំណុះ ៤ លីត្រ ដល់គ្រួសារជនបទដែលបានទិញ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធមួយផ្នែក ហើយអ្នកទិញត្រូវបង់ថ្លៃសល់ពីការឧបត្ថម្ភធននេះ រំលស់ប្រចាំខែដោយគ្មានការប្រាក់មក ម.អ.ជ. វិញ ក្នុងរយៈពេល ៤ឆ្នាំ។ ក្រោយពេលសងរំលស់អស់ជាស្ថាពរ ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

ក្នុងឆ្នាំ២០២០ មានគ្រួសារជនបទចំនួន ៩.៨៣៤ គ្រួសារ ស្មើនឹង ៤៥.២៣៦ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៣. កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ៖ គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់អ្នកផ្គត់ផ្គង់អគ្គិសនីនៅជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់ អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋ

គ្រប់គ្រួសារអាចតភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។ ក្នុងឆ្នាំ២០២០ អ្នកកាន់អាជ្ញាបណ្ណចំនួន ១៤៤ ស្មើនឹង ៣.០៧៨,២៣ គីឡូម៉ែត្រ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៤. កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី៖ គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី។

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណចំនួន ៣២៧ តំបន់អាជ្ញាបណ្ណ ដែលក្នុងនោះ ៣២៤ តំបន់អាជ្ញាបណ្ណ បានទទួលថវិកាឧបត្ថម្ភធន និង ៣ តំបន់អាជ្ញាបណ្ណ ពុំទាន់ស្នើសុំថវិកានៅឡើយ និងដល់អ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីនៅក្នុងបរិវេណផ្សារចំនួន ៦៤ តំបន់ផ្សារ ដែលក្នុងនោះ ៥៣ តំបន់ផ្សារ បានទទួលថវិកាឧបត្ថម្ភធន និង ១១ តំបន់ផ្សារ ពុំទាន់ស្នើសុំថវិកានៅឡើយ។

៥. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌៖ គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌នៅជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយ ម.អ.ជ. ផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ ដុល្លារអាមេរិក ក្នុង១គ្រួសារ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ចំណាយលើសម្ភារ និងឈ្នួលពលកម្ម ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

ក្នុងឆ្នាំ២០២០ មានគ្រួសារជនបទក្រីក្រមានប័ណ្ណសមធម៌ចំនួន ៣.១៤៨ គ្រួសារ ស្មើនឹង ១៤.៤៨០ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៦. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភធន ៥០ ដុល្លារអាមេរិក ក្នុង១គ្រួសារ៖ គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រនៅជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី ដោយ ម.អ.ជ. ផ្តល់ប្រាក់ឧបត្ថម្ភធន ៥០ ដុល្លារអាមេរិក ក្នុង១គ្រួសារ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់ចំណាយលើសម្ភារ និងឈ្នួលពលកម្ម ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

ក្នុងឆ្នាំ២០២០ មានគ្រួសារជនបទក្រីក្រមានប័ណ្ណសមធម៌ចំនួន ២.៤១៦ គ្រួសារ ស្មើនឹង ១១.១១៣ នាក់ បានទទួលផលប្រយោជន៍ដោយផ្ទាល់ក្រោមកម្មវិធីនេះ។

៧. កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនី ដើម្បីបូមទឹកធ្វើកសិកម្ម៖ គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់ សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះត្រឹមតែ ៤៨០ រៀល ក្នុង១គីឡូវ៉ាត់ម៉ោង សម្រាប់ការប្រើប្រាស់អគ្គិសនីបូមទឹកធ្វើកសិកម្មនៅពេលយប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីបូមទឹកធ្វើកសិកម្មនៅពេលថ្ងៃពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីតង់ស្យុងមធ្យម (MV) និងតង់ស្យុងទាប (LV) ដើម្បីបូមទឹកធ្វើកសិកម្មសរុបចំនួន ១៣៩,៦៥៣ គីឡូម៉ែត្រ។

លទ្ធផលនៃកិច្ចខំប្រឹងប្រែងខាងលើ បានផ្តល់នូវប្រយោជន៍ដោយផ្ទាល់ និងដោយប្រយោលជាច្រើនជូនដល់ប្រជាជនរាប់លានគ្រួសារ ដែលប្រការនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពរឹងមាំ និងការរីកចម្រើនយ៉ាងពិតប្រាកដក្នុងការរួមចំណែកការអភិវឌ្ឍប្រទេសកម្ពុជា ដើម្បីស្ថាបនាបាននូវគ្រឹះដ៏រឹងមាំសម្រាប់កិច្ចអភិវឌ្ឍន៍ឲ្យមាននិរន្តរភាពសេដ្ឋកិច្ច និងសង្គមជាតិ។ របាយការណ៍នេះ បានរៀបចំឡើងជាភាសាខ្មែរ និងភាសាអង់គ្លេស។

យើងខ្ញុំសូមសំដែងនូវសេចក្តីសោមនស្សរីករាយ ជាពិសេសជូនចំពោះសមាជិកក្រុមប្រឹក្សាភិបាលអគ្គិសនីកម្ពុជាសម្រាប់ការចូលរួមចំណែកការគាំទ្រ និងការណែនាំកន្លងមក ក្នុងការរុញច្រានពីការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទឲ្យបានទទួលនូវផលប្រយោជន៍គ្រប់ៗគ្នាពីការអភិវឌ្ឍអគ្គិសនីរបស់អគ្គិសនីកម្ពុជា។

**រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី**
**អគ្គនាយកអគ្គិសនីកម្ពុជា**

ELECTRICITE DU CAMBODGE

**កែវ រតនៈ**

# មាតិកា


ទំព័រ

**ជំពូកទី១ គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនី និងគោលនយោបាយពាក់ព័ន្ធជាមួយការអភិវឌ្ឍតំបន់ជនបទ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ ............ ៩**

១.១ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភា ............ ៩

១.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភា ............ ៩

**ជំពូកទី២ ព័ត៌មានស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ............ ១១**

២.១ ការបង្កើតមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ............ ១១

២.២ រចនាសម្ព័ន្ធគ្រប់គ្រង ............ ១១

២.៣ បណ្ណាល័យ ............ ១១

២.៤ អាសយដ្ឋាន ............ ១២

២.៥ ប្រភពមូលនិធិ ............ ១៣

២.៦ ថវិកាជំនួយដែល ម.អ.ជ. បានទទួល និងប្រើប្រាស់ ............ ១៣

**ជំពូកទី៣ ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ............ ១៥**

៣.១ គោលបំណង ............ ១៥

៣.២ បេសកកម្ម ............ ១៥

៣.៣ កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ............ ១៦

៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ............ ១៦

៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ............ ១៦

៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ............ ១៦

៣.៣.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្តនិងរាជធានី ............ ១៦

៣.៣.៥ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ............ ១៦

៣.៣.៦ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភ ៥០ដុល្លារអាមេរិក ក្នុង១គ្រួសារ ........ ១៧
៣.៣.៧ កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ........ ១៧
៣.៤ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនីមួយៗ ........ ១៧
៣.៤.១ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ . ១៧
៣.៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ........ ១៨
៣.៤.៣ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ........ ២០
៣.៤.៤ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជា សម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី ........ ២៤
៣.៤.៥ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ........ ២៤
៣.៤.៦ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយផ្តល់ប្រាក់ឧបត្ថម្ភ ៥០ដុល្លារអាមេរិក ក្នុង១គ្រួសារ ........ ២៥
៣.៤.៧ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនី សម្រាប់បូមទឹកធ្វើកសិកម្ម ........ ២៧
៣.៥ ការតែងតាំង ម.អ.ជ. ជាភ្នាក់ងារឯករាជ្យ ដើម្បីធ្វើជាសាក្សី និងវាយតម្លៃការធ្វើតេស្តរោងចក្រអគ្គិសនីដើរដោយ Solar Photovoltaic (PV) ........ ២៧
**ជំពូកទី៤ ព័ត៌មានស្តីពីវឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធីនីមួយៗដែលបានអនុវត្តដោយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ ........ ២៨**
៤.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ........ ២៨
៤.១.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ........ ២៨
៤.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ (SHS) ........ ២៨
៤.២.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ........ ២៨
៤.២.២ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីប្រព័ន្ធ SHS ........ ៣១
៤.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ .. ៣២
៤.៣.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ........ ៣២
៤.៣.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ........ ៣៦

៤.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃ ផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រ កម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី ......... ៣៨

៤.៥ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌.......................... ៤៧

៤.៥.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ............................. ៤៧

៤.៥.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់ គ្រួសារក្រីក្រ ................................................................................. ៤៨

៤.៦ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយផ្តល់ប្រាក់ឧបត្ថម្ភធន ចំនួន ៥០ ដុល្លាអាមេរិក ក្នុង១គ្រួសារ ................................................................... ៤៩

៤.៦.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ............................. ៤៩

៤.៦.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់ គ្រួសារក្រីក្រ ................................................................................. ៥០

៤.៧ កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ............................ ៥១

៤.៧.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី ............................. ៥១

៤.៧.២ សកម្មភាពចុះពិនិត្យការសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដើម្បីបូមទឹកធ្វើកសិកម្ម ....................................................... ៥៣

**ជំពូកទី៥** **ព័ត៌មានស្តីពីការតែងតាំង ម.អ.ជ. ឆ្លាក់ខាងឯករាជ្យ ដើម្បីធ្វើជាសាក្សី និងវាយតម្លៃការធ្វើតេស្តរោងចក្រអគ្គិសនីដើរដោយ Solar Photovoltaic (PV) ............................................................................ ៥៤**

**ឧបសម្ព័ន្ធទី១** : បញ្ជីឈ្មោះភូមិបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ក្នុងឆ្នាំ២០២០ ........ ៥៥

**ឧបសម្ព័ន្ធទី២** : ផែនទីបង្ហាញពីខេត្តបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ក្នុងឆ្នាំ២០២០.. ៦១

**ឧបសម្ព័ន្ធទី៣** : ព័ត៌មានសង្ខេបស្តីពីការចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយ អគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០ ............................ ៦២

**ឧបសម្ព័ន្ធទី៤** : ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែ បណ្តាញបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្ន តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០ ....................... ៧២

**ឧបសម្ព័ន្ធទី៥** : បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្តប់ តាមខេត្តនីមួយៗ ក្រោមថវិកា ផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០ .................. ៨២

**ឧបសម្ព័ន្ធទី៦** : ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការ ផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារ

| | | | |
|---|---|---|---|
| | | អភិវឌ្ឍន៍អាល្លឺម៉ង់ ក្នុងឆ្នាំ២០២០ ........................................................ | ១១២ |
| **ឧបសម្ព័ន្ធទី៧** | : | ព័ត៌មានសង្ខេបស្ដីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........................................ | ១១៣ |
| **ឧបសម្ព័ន្ធទី៨** | : | ព័ត៌មានសង្ខេបស្ដីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ................................ | ១១៥ |
| **ឧបសម្ព័ន្ធទី៩** | : | បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្ដប់ តាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........................................................................... | ១១៧ |
| **ឧបសម្ព័ន្ធទី១០** | : | ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២០ ...................... | ១២៣ |
| **ឧបសម្ព័ន្ធទី១១** | : | ព័ត៌មានសង្ខេបស្ដីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........................................ | ១២៤ |
| **ឧបសម្ព័ន្ធទី១២** | : | ព័ត៌មានសង្ខេបស្ដីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានបណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ................................ | ១២៦ |
| **ឧបសម្ព័ន្ធទី១៣** | : | បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្ដប់ តាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្រោមកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........................................................................... | ១២៧ |
| **ឧបសម្ព័ន្ធទី១៤** | : | ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្ដល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្នុងឆ្នាំ២០២០ ...................... | ១៣០ |
| **ឧបសម្ព័ន្ធទី១៥** | : | ព័ត៌មានសង្ខេបស្ដីពីកិច្ចសន្យាសាងសង់ហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីផ្ដល់ជូនសេវាករដើម្បីបូមទឹកធ្វើកសិកម្ម តាមខេត្តនីមួយៗ ក្រោមកម្មវិធីកម្មវិធីផ្ដល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងឆ្នាំ២០២០ .................................................. | ១៣១ |
| **ឧបសម្ព័ន្ធទី១៦** | : | ព័ត៌មានសង្ខេបស្ដីពីហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីគ្រោងសាងសង់ជាប់កិច្ចសន្យា និងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្ន តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្ដល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងឆ្នាំ២០២០....... | ១៣៣ |
| **ឧបសម្ព័ន្ធទី១៧** | : | បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្ដប់ តាមខេត្តនីមួយៗ ក្រោមថវិកាផ្ដល់ដោយអគ្គិសនីកម្ពុជា ក្រោមកម្មវិធីផ្ដល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងឆ្នាំ២០២០........................................................................... | ១៣៦ |
| **ឧបសម្ព័ន្ធទី១៨** | : | ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីផ្ដល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងឆ្នាំ២០២០........................................................................ | ១៣៧ |

# បញ្ជីតារាង

ទំព័រ


**តារាងទី១** : ព័ត៌មានស្តីពីចំនួនប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ដែលបានដំឡើងជូនគ្រួសារជនបទ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០ ........ ២៩

**តារាងទី២** : ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០ ........ ៣០

**តារាងទី៣** : ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួច តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០ ........ ៣៣

**តារាងទី៤** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនី តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០ ........ ៣៥

**តារាងទី៥** : ព័ត៌មានសង្ខេបស្តីពីចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២០ (ខួបឆ្នាំ២០១៩)........ ៣៩

**តារាងទី៦** : ព័ត៌មានសង្ខេបស្តីពីចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២០ (ខួបឆ្នាំ២០២០)........ ៤៣

**តារាងទី៧** : ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា និងចំនួនគ្រួសារជនបទ បានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........ ៤៧

**តារាងទី៨** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនី តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ ........ ៤៨

**តារាងទី៩** : ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា និងចំនួនគ្រួសារជនបទ បានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ៥០ ដុល្លារអាមេរិក ក្នុង ១គ្រួសារ ក្នុងឆ្នាំ២០២០ ........ ៤៩

**តារាងទី១០** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនី តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ៥០ដុល្លារអាមេរិក ក្នុង ១គ្រួសារ ក្នុងឆ្នាំ២០២០ ........ ៥០

**តារាងទី១១** : ព័ត៌មានសង្ខេបស្តីពីចំនួនហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីគ្រោងសាងសង់ជាប់កិច្ចសន្យា និងហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្ន តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០........ ៥២

**តារាងទី១២** : ចំនួនភូមិសរុប និងចំនួនភូមិបានទទួលហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម ក្នុងឆ្នាំ២០២០ ........ ៥២

# ជំពូកទី១
# គោលនយោបាយ និងយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យ
# ថាមពលអគ្គិសនី និងគោលនយោបាយពាក់ព័ន្ធជាមួយការអភិវឌ្ឍតំបន់ជនបទ
# និងការប្រើប្រាស់ថាមពលកកើតឡើងវិញ

## ១.១ គោលនយោបាយវិស័យថាមពលរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភា

ថាមពលអគ្គិសនី គឺជាផលិតផលមួយមានសារៈសំខាន់ណាស់សម្រាប់សង្គម និងសេដ្ឋកិច្ច។ ថាមពលអគ្គិសនី មិនត្រឹមតែជាផលិតផលមួយសម្រាប់បំរើឲ្យជីវភាពរស់នៅប៉ុណ្ណោះទេ តែក៏ជាផលិតផលមួយចាំបាច់សម្រាប់ជំរុញការអភិវឌ្ឍវិស័យផ្សេងៗទៀតរបស់ប្រទេសជាតិផងដែរ។ ដូច្នេះ ការអភិវឌ្ឍវិស័យថាមពលអគ្គិសនី គឺជាគន្លឹះដ៏សំខាន់សម្រាប់ជំរុញឲ្យមានកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យផ្សេងៗ ការអភិវឌ្ឍតំបន់ជនបទ និងការបង្កើនសុខដុមនីយភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ។ នៅក្នុងអាណត្តិទី៦ នៃរដ្ឋសភា **រាជរដ្ឋាភិបាលកម្ពុជា** មានមហិច្ឆតាគ្រប់គ្រង និងជំរុញការអភិវឌ្ឍវិស័យថាមពលអគ្គិសនីដើម្បី "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា"។

ក្នុងនីតិកាលទី៦ នៃរដ្ឋសភា ក្នុងក្របខណ្ឌនៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ចំពោះការអភិវឌ្ឍវិស័យថាមពលអគ្គិសនី រាជរដ្ឋាភិបាលនឹងផ្តោតអាទិភាពលើ៖

- អាទិភាពទី១- បន្តបញ្ចុះថ្លៃអគ្គិសនីឲ្យអ្នកប្រើប្រាស់ ពង្រីកវិសាលភាពគ្របដណ្តប់នៃបណ្តាញផ្គត់ផ្គង់អគ្គិសនីរបស់ប្រព័ន្ធបណ្តាញជាតិឲ្យបានគ្រប់ទីកន្លែងទូទាំងប្រទេស បង្កើនស្ថិរភាព និងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី (ចតុកោណយុទ្ធសាស្ត្រទី២-មុំទី១)។
- អាទិភាពទី២- បន្តពង្រីកការតបណ្តាញអគ្គិសនីដែលមានថ្លៃអគ្គិសនីទាបជូនកម្មករ និយោជិត សិស្ស និស្សិតនៅតាមផ្ទះជួល (ចតុកោណយុទ្ធសាស្ត្រទី៣-មុំទី១)។
- អាទិភាពទី៣- បន្តជំរុញការអភិវឌ្ឍនៅតំបន់ជនបទឲ្យរស់រវើក ដោយបន្តវិនិយោគលើការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនីដែលមានថ្លៃសមរម្យ មានស្ថិរភាព និងមានគុណភាពឲ្យដល់តំបន់ជនបទ (ចតុកោណយុទ្ធសាស្ត្រទី៤-មុំទី១)។
- អាទិភាពទី៤- បន្តលើកទឹកចិត្ត និងបង្កើនការវិនិយោគលើប្រភពថាមពលស្អាត និងថាមពលកកើតឡើងវិញ ពិសេសប្រភពថាមពលពន្លឺព្រះអាទិត្យ ទន្ទឹមនឹងការកាត់បន្ថយការផលិតថាមពលពីប្រភពមិនស្អាត ដើម្បីធានាសន្តិសុខថាមពលរយៈពេលវែង (ចតុកោណយុទ្ធសាស្ត្រទី៤-មុំទី៤)។

## ១.២ យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យថាមពលអគ្គិសនីរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៦ នៃរដ្ឋសភា

ក្នុងគោលបំណង "ឈានទៅសម្រេចឲ្យបានការផ្គត់ផ្គង់ថាមពលអគ្គិសនីមួយគ្រប់គ្រាន់ មានចីរភាព អាចទុកចិត្តបាន មានគុណភាព និងមានថ្លៃសមរម្យ សម្រាប់អ្នកប្រើប្រាស់គ្រប់ប្រភេទ នៅគ្រប់ទីកន្លែងទូទាំងព្រះរាជាណាចក្រកម្ពុជា" ក្រសួងរ៉ែ និងថាមពលដែលជាស្ថាប័នទទួលបន្ទុកវិស័យថាមពលរបស់រាជរដ្ឋាភិបាល បានដាក់ចេញនូវយុទ្ធសាស្ត្រចំនួន ៩ចំណុច ដូចខាងក្រោម៖

ទី១ - ធ្វើបច្ចុប្បន្នកម្មផែនការមេអភិវឌ្ឍវិស័យអគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាឡើងវិញ។

ទី២ - បន្តអភិវឌ្ឍសមត្ថភាពផលិត បញ្ជូន និងចែកចាយ សំដៅធ្វើយ៉ាងណាឲ្យកម្ពុជាមានប្រភពអគ្គិសនីគ្រប់គ្រាន់ ទាន់តាមកំណើននៃសេចក្តីត្រូវការប្រើប្រាស់ ឲ្យការផ្គត់ផ្គង់ប្រភពអគ្គិសនីពីបណ្តាញជាតិអាចគ្របដណ្តប់គ្រប់ទីកន្លែងទូទាំងប្រទេស រួមទាំងតំបន់ជនបទ និងឲ្យការចែកចាយអគ្គិសនីអាចគ្របដណ្តប់គ្រប់ភូមិទូទាំងប្រទេស។ ក្នុងគោលបំណងកាត់បន្ថយភាពក្រីក្រ លើកកម្ពស់កម្រិតជីវភាពរស់នៅ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រជាជននៅតំបន់ជនបទ នៅក្នុងនីតិកាលទី៦ នៃរដ្ឋសភានេះ រាជរដ្ឋាភិបាលកម្ពុជានឹងបន្តជំរុញការអភិវឌ្ឍនៅតំបន់ជនបទឲ្យរស់រវើក ដោយបន្តវិនិយោគលើការពង្រីកភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី ដែលមានថ្លៃសមរម្យ មានស្ថិរភាព និងមានគុណភាពឲ្យដល់តំបន់ជនបទនៅទូទាំងប្រទេស។

ទី៣ - ជំរុញការភ្ជាប់បណ្តាញផ្គត់ផ្គង់អគ្គិសនីឲ្យទីតាំងត្រូវការប្រើប្រាស់អគ្គិសនី ជាពិសេសលំនៅដ្ឋានដែលមិនទាន់មានអគ្គិសនីប្រើប្រាស់ ទាំងនៅក្នុងតំបន់ទីប្រជុំជន និងទាំងនៅតំបន់ជនបទ ដើម្បីសម្រេចគោលដៅឲ្យគ្រួសារជាង ៩០% មានអគ្គិសនីប្រើប្រាស់នៅឆ្នាំ២០២៣។

ទី៤ - កែលម្អការផ្តល់សេវាផ្គត់ផ្គង់អគ្គិសនី ក្នុងគោលដៅធ្វើយ៉ាងណាឲ្យការផ្គត់ផ្គង់មានភាពគ្រប់គ្រាន់ និងមាន ២៤ ម៉ោង មានគុណភាព សុវត្ថិភាព និងអាចទុកចិត្តបាន មានថ្លៃសមរម្យ និងមានភាពយុត្តិធម៌ក្នុងការវាស់វែង និងកត់ត្រាបរិមាណផ្គត់ផ្គង់នៅគ្រប់ទីកន្លែង ទាំងនៅតំបន់ទីប្រជុំជន និងទាំងនៅតំបន់ជនបទ។

ទី៥ - រៀបចំ និងអនុវត្តផែនការបន្ថយថ្លៃអគ្គិសនី ព្រមទាំងសិក្សារកលទ្ធភាពបន្ថយថ្លៃអគ្គិសនីបន្ថែមទៀតក្នុងគោលដៅសម្រួលដល់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ និងជំរុញការវិនិយោគនៅកម្ពុជា។

ទី៦ - ពង្រឹងយន្តការស្ថាប័ន ដើម្បីធ្វើយ៉ាងណាឲ្យទំនាក់ទំនង តួនាទី ភារកិច្ច ឋានានុក្រម និងឯករាជ្យភាពរវាងស្ថាប័ន និងអង្គភាពក្នុងវិស័យថាមពល ប្រព្រឹត្តទៅដោយច្បាស់លាស់ និងមានប្រសិទ្ធភាព។

ទី៧ - ទាក់ទាញឲ្យឯកជនចូលរួមវិនិយោគជាមួយអគ្គិសនីកម្ពុជា ដើម្បីធ្វើយ៉ាងណាឲ្យមានការវិនិយោគគ្រប់គ្រាន់ ដោយបើកឲ្យឯកជនចូលរួមធ្វើអាជីវកម្មអគ្គិសនី ប៉ុន្តែរក្សាការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជាលើអាជីវកម្មក្នុងបណ្តាញជាតិដែលជាស្នូលនៃអាជីវកម្មទាំងមូល។

ទី៨ - ប្រើប្រាស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងការធ្វើ Cross-Subsidy បន្ថយគម្លាតថ្លៃ និងក្នុងការផ្ទេរទុនទៅជួយអភិវឌ្ឍនៅតំបន់ជនបទដាច់ស្រយាល ដើម្បីជានាសមធម៌ក្នុងការទទួលបានសេវាអគ្គិសនីរវាងតំបន់ទីប្រជុំជន និងតំបន់ជនបទ។

ទី៩ - កាត់បន្ថយផលប៉ះពាល់បរិស្ថានធម្មជាតិ និងសង្គមឲ្យបានជាអតិបរមា ចូលរួមប្រើប្រាស់ប្រភពថាមពលស្អាត និងចីរភាពក្នុងកម្រិតដែលមិនប៉ះពាលធំដុំ ចូលរួមក្នុងកិច្ចសហប្រតិបត្តិការវិស័យថាមពលក្នុងក្របខណ្ឌតំបន់ និងក្របខណ្ឌអន្តរជាតិ។

## ជំពូកទី២
## ព័ត៌មានស្តីពីមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

### ២.១ ការបង្កើតនាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

ម.អ.ជ. ដំបូងឡើយបង្កើតឡើងតាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ដើម្បីជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ។ ក្នុងឆ្នាំដំបូងនៃប្រតិបត្តិការការងារ ម.អ.ជ. បានប្រើប្រាស់ថវិកាដែលបានផ្តល់ដោយធនាគារពិភពលោក ក្រោមគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូន និងថវិកាបដិភាគរបស់រាជរដ្ឋាភិបាលកម្ពុជា។ បន្ទាប់ពីគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ និងខ្សែបញ្ជូនបានបញ្ចប់នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១២ និងពុំមានថវិកាសម្រាប់ដំណើរការស្ថាប័ននេះ។ នៅថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ព្រះរាជក្រឹត្យថ្មីមួយទៀតលេខ នស/រកត/០៨១២/៧៣៤ ធ្វើវិសោធនកម្មមាត្រាខ្លះនៃព្រះរាជក្រឹត្យចាស់ ដោយផ្ទេរ ម.អ.ជ. ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អគ្គិសនីកម្ពុជា ដើម្បីឲ្យកម្ពុជាខ្លួនឯងអាចម្ចាស់ការបន្តប្រតិបត្តិការការងាររបស់ ម.អ.ជ. ផង និងក៏នៅតែអាចទទួលនូវអំណោយ និងជំនួយនានាពីខាងក្រៅមកជួយអភិវឌ្ឍន៍អគ្គិសនីភាវូបនីយកម្មជនបទកម្ពុជាបានផង។ តាមព្រះរាជក្រឹត្យថ្មីនេះ អគ្គិសនីកម្ពុជាបានបង្កើតនាយកដ្ឋានថ្មី[1] មួយហៅថា **"នាយកដ្ឋានមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ (ម.អ.ជ.)"** ។

នេះជាជំហានដ៏ធំមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការជំរុញការអភិវឌ្ឍអគ្គិសនីភាវូបនីយកម្មជនបទ ដែលនឹងទាក់ទាញ និងលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគក្នុងការធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទ ដើម្បីជួយជំរុញការអភិវឌ្ឍនៅតំបន់ជនបទ និងដើម្បីអាចផ្តល់លទ្ធភាពឲ្យប្រជាជនក្រីក្រនៅតំបន់ជនបទកាន់តែច្រើនគ្រួសារមានអគ្គិសនីយកទៅប្រើប្រាស់សម្រាប់បំភ្លឺ ប្រកបរបរអាជីវកម្ម សិប្បកម្ម និងប្រើជាផលប្រយោជន៍ដទៃទៀត ដើម្បីលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ក៏ដូចជាដើម្បីជាផលប្រយោជន៍ទូទៅដល់សង្គមជាតិ។

### ២.២ រចនាសម្ព័ន្ធគ្រប់គ្រង

ម.អ.ជ. ប្រតិបត្តិការស្របតាមលក្ខន្តិកៈរបស់អគ្គិសនីកម្ពុជា និងមានលក្ខណៈសង្គមកិច្ច និងមានគណនីដាច់ដោយឡែក។

### ២.៣ បណ្ណាល័យ

ម.អ.ជ. ក៏មានបណ្ណាល័យសម្រាប់សាធារណជន ដែលមានបំណងចង់យល់ដឹងពីកម្មវិធីរបស់ ម.អ.ជ. របាយការណ៍ និងការរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទក្នុងព្រះរាជាណាចក្រកម្ពុជា។

[1] សេចក្តីសម្រេចលេខ ០៨៩៨សសរ.អក.រប ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១២ ស្តីពីការកំណត់ថ្នាក់អង្គភាពមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទក្នុងអង្គការលេខ និងរចនាសម្ព័ន្ធគ្រប់គ្រងអគ្គិសនីកម្ពុជា។





## ២.៤ អាសយដ្ឋាន

អាសយដ្ឋាន ម.អ.ជ. ស្ថិតនៅអាគារលេខ២០៥ ផ្លូវជាតិលេខ៥ សង្កាត់គីឡូម៉ែត្រលេខ៦ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។ គេហទំព័ររបស់ ម.អ.ជ. គឺ www.ref.gov.kh ។






## ២.៥ ប្រភពមូលនិធិ

ប្រភពមូលនិធិដល់ ម.អ.ជ.[2] មានដូចខាងក្រោម៖

១. កញ្ចប់ថវិកាសង្គមកិច្ចដែលបានគ្រោងក្នុងបញ្ជីថ្លៃលក់អគ្គិសនីរបស់អគ្គិសនីកម្ពុជា និងអំណោយដទៃទៀតរបស់អគ្គិសនីកម្ពុជា ប្រសិនបើមាន។

២. អំណោយ និងជំនួយឥតសំណងដែលប្រភព និងលក្ខខណ្ឌនៃការផ្តល់ត្រូវបានទទួលការឯកភាពពីក្រសួងរ៉ែ និងថាមពល និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣. ថវិកាពីរាជរដ្ឋាភិបាលកម្ពុជា។

## ២.៦ ថវិកាជំនួយដែល ម.អ.ជ. បានទទួល និងប្រើប្រាស់

ក្នុងឆ្នាំ២០២០ ម.អ.ជ. ទទួលបានថវិកាពីអគ្គិសនីកម្ពុជាចំនួន ៣៧៦ ពាន់លានរៀល សម្រាប់អនុវត្តន៍កម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ។ ថវិកាទទួលបានពីអគ្គិសនីកម្ពុជាក៏សម្រាប់ចំណាយប្រតិបត្តការរបស់ ម.អ.ជ. ផងដែរ។

ថវិកាទទួលបាននេះ ម.អ.ជ. បានយកទៅប្រើប្រាស់ក្នុងការអនុវត្តកម្មវិធីរុញផ្លែផ្កានៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ ដូចខាងក្រោម៖

១. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ។

២. កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

៣. កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។

---

[2] ព្រះរាជក្រឹត្យលេខ នស/រកត/០៨១២/៧៣៤ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០១២ ស្តីពីវិសោធនកម្មលើមាត្រា២ មាត្រា៥ និងមាត្រា៧ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ. និងលើមាត្រា៤ថ្មីនៃព្រះរាជក្រឹត្យលេខ នស/រកត/០១០៨/០៦៤ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៨ ស្តីពីវិសោធនកម្មមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើត ម.អ.ជ.។

៤. កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្រួប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្តនិងរាជធានី។
៥. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌។
៦. កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភធន ៥០ ដុល្លារអាមេរិក ក្នុង១គ្រួសារ ។
៧. កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម។

## ជំពូកទី៣
## ព័ត៌មានស្តីពីគោលបំណង បេសកកម្ម និងកម្មវិធីរុញច្រានផ្ដួចផ្ដើមនៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទរបស់មូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

### ៣.១ គោលបំណង

គោលបំណងរបស់ ម.អ.ជ.[3] មានដូចខាងក្រោម៖

១. ជំរុញឲ្យមានសមធម៌ក្នុងការទទួលសេវាកម្មអគ្គិសនី ដោយជួយឲ្យប្រជាជននៅជនបទបានទទួលអគ្គិសនីប្រើប្រាស់តាមថ្លៃ ដែលអាចជាវបានសម្រាប់សេដ្ឋកិច្ច សង្គម និងលំនៅដ្ឋាន រួមចំណែកកាត់បន្ថយភាពក្រីក្រ។

២. ជំរុញ និងលើកទឹកចិត្តផ្នែកឯកជនឲ្យចូលរួមវិនិយោគធ្វើសេវាកម្មអគ្គិសនីនៅតំបន់ជនបទប្រកបដោយចីរភាព ជាពិសេសក្នុងការអនុវត្តបច្ចេកវិទ្យាថ្មី និងថាមពលកកើតឡើងវិញដែលមានលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្មសមស្រប។

### ៣.២ បេសកកម្ម

ម.អ.ជ. មានបេសកកម្ម ដូចខាងក្រោម៖

១. ជម្រុញវិសាលភាពអគ្គិសនីភាវូបនីយកម្មជនបទប្រកបដោយសមភាព ដោយសម្រួលឲ្យប្រជាពលរដ្ឋជនបទទទួលបានអគ្គិសនីប្រើប្រាស់ជាលក្ខណៈសេដ្ឋកិច្ច សង្គមកិច្ច និងគ្រួសារ។

២. ផ្តល់ការគាំទ្រដល់ការរៀបចំ និងអនុវត្តគម្រោងអគ្គិសនីភាវូបនីយកម្មជនបទ។

៣. ផ្តល់ការគាំទ្រ និងជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយការផ្តល់ជាប្រាក់កម្ចីអនុគ្រោះគ្មានការប្រាក់ និងផ្តល់ជាប្រាក់ឧបត្ថមធន (ប្រាក់អំណោយ)។

៤. ផ្តល់ការគាំទ្រ និងជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ អាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

៥. ផ្តល់ការគាំទ្រ និងជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីឯកជននៅតំបន់ជនបទដែលមានអាជ្ញាបណ្ណស្របច្បាប់ អាចមានទុនសម្រាប់ធ្វើការវិនិយោគពង្រីកហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។

៦. ផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនី ដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្តនិងរាជធានី និង

៧. ផ្តល់ការគាំទ្រ និងជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេល

---

[3] មាត្រា៣ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២០៤/០៤៨ ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០០៤ ស្តីពីការបង្កើតស្ថាប័ន ម.អ.ជ.។

យប់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនី នៅពេលថ្ងៃចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

៨. ជម្រុញការធ្វើពាណិជ្ជកម្មបច្ចេកវិទ្យាថាមពលកកើតឡើងវិញដែលត្រូវបានទទួលស្គាល់ជាលក្ខណៈបច្ចេកទេស និងពាណិជ្ជកម្ម។

អាស្រ័យនឹងលក្ខខណ្ឌថវិកាដែល ម.អ.ជ. ទទួលបានពីប្រភពផ្សេងៗ ម.អ.ជ. នឹងប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធានដែលខ្លួនមាន ដើម្បីសម្រេចឲ្យបាននូវបេសកកម្មខាងលើ។

## ៣.៣ កម្មវិធីរុញច្រានផ្នែកនៃការអភិវឌ្ឍអគ្គិសនីឆ្ពោះទៅប្រជាពលរដ្ឋនៅជនបទ

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានអនុវត្តកម្មវិធី ដូចខាងក្រោម៖

### ៣.៣.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទ ដើម្បីឲ្យគ្រួសារក្រីក្ររស់នៅតំបន់ជនបទអាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយការផ្តល់ឥណទានអនុគ្រោះគ្មានការប្រាក់ឲ្យគ្រួសារជនបទខ្ចីយកទៅ៖ ១- បង់ថ្លៃភ្ជាប់ចរន្តឲ្យអ្នកផ្គត់ផ្គង់ ២- បង់ថ្លៃប្រាក់កក់ឲ្យអ្នកផ្គត់ផ្គង់ ៣- ចំណាយលើការទិញ និងរាយខ្សែពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះរបស់ខ្លួន និង៤- ចំណាយលើការរៀបចំខ្សែបណ្តាញ និងឧបករណ៍អគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

### ៣.៣.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យគ្រួសារជនបទរស់នៅតំបន់ដាច់ស្រយាលដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរអាចទទួលបានអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ។

### ៣.៣.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលឲ្យអ្នកផ្គត់ផ្គង់អគ្គិសនីឯកជននៅតំបន់ជនបទ ដែលមានអាជ្ញាបណ្ណស្របច្បាប់ អាចមានទុនសម្រាប់វិនិយោគពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន ដើម្បីឲ្យប្រជាពលរដ្ឋគ្រប់គ្រួសារអាចមានភ្ជាប់ចរន្តប្រើប្រាស់តាមលទ្ធភាពរបស់ខ្លួន។

### ៣.៣.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនី ក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្តនិងរាជធានី

គោលបំណងនៃកម្មវិធីនេះ គឺផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី។

### ៣.៣.៥ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (P2P for ID Poor HH)

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌នៅតំបន់ជនបទដោយជួយគ្រួសារមាន

ចំណូលទាប និងងាយរងផលប៉ះពាល់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ១០០ដុល្លារអាមេរិក ក្នុង១គ្រួសារក្រីក្រ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់៖ ១- ចំណាយលើសម្ភារ និងពលកម្មរាយខ្សែបណ្តាញសេវាកម្មក្នុងប្រវែង ១៥០ម៉ែត្រ ពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះគ្រួសារមានប័ណ្ណក្រីក្រ និង ២-ចំណាយលើសម្ភារ និងពលកម្មដំឡើងសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

កម្មវិធីនេះបានទទួលថវិកាជំនួយពីអគ្គិសនីកម្ពុជា (EDC) ចំនួន ៣០០.០០០ ដុល្លារអាមេរិក សម្រាប់អនុវត្តន៍ក្នុងខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងបណ្តាខេត្តដទៃទៀត។ ចំនួនគោលដៅគ្រួសារក្រីក្រមានបណ្ណសមធម៌គ្រោងទទួលផលក្រោមកម្មវិធីនេះគឺ ៣.០០០ គ្រួសារ។

### ៣.៣.៦ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភធន ចំនួន ៥០ ដុល្លារអាមេរិក ក្នុង ១ គ្រួសារ

គោលបំណងនៃកម្មវិធីនេះ គឺជួយដល់គ្រួសារក្រីក្រនៅតំបន់ជនបទដោយជួយគ្រួសារមានចំណូលទាប និងងាយរងផលប៉ះពាល់អាចទទួលបានការតភ្ជាប់ចរន្តអគ្គិសនីពីប្រព័ន្ធផ្គត់ផ្គង់អគ្គិសនីដោយការផ្តល់ថវិកាឧបត្ថម្ភធនចំនួន ៥០ ដុល្លារអាមេរិក ក្នុង១គ្រួសារក្រីក្រ តាមរយៈអ្នកកាន់អាជ្ញាបណ្ណសម្រាប់៖ ១-ចំណាយលើសម្ភារ និងពលកម្មរាយខ្សែបណ្តាញសេវាកម្មក្នុងប្រវែង ១៥០ម៉ែត្រ ពីចំណុចភ្ជាប់ចរន្តមកដល់ផ្ទះគ្រួសារក្រីក្រ និង ២-ចំណាយលើសម្ភារ និងពលកម្មដំឡើងសម្ភារអគ្គិសនីក្នុងផ្ទះ ដើម្បីតភ្ជាប់ចរន្តអគ្គិសនីចូលផ្ទះ។

កម្មវិធីនេះបានទទួលថវិកាជំនួយពីអគ្គិសនីកម្ពុជា (EDC) ចំនួន ៥០០.០០០ ដុល្លារអាមេរិក សម្រាប់អនុវត្តន៍ក្នុងក្របខណ្ឌទូទាំងប្រទេស។ ចំនួនគោលដៅគ្រួសារក្រីក្រគ្រោងទទួលផលក្រោមកម្មវិធីនេះគឺ ១០.០០០ គ្រួសារ។

### ៣.៣.៧ កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម

គោលបំណងនៃកម្មវិធីនេះ គឺជួយសម្រួលដល់គ្រួសារក្រីក្ររស់នៅតំបន់ជនបទទទួលបានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិផ្ទាល់សម្រាប់ការបូមទឹកធ្វើកសិកម្មនៅតម្លៃអនុគ្រោះសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលយប់ចាប់ពីម៉ោង ៩:០០យប់ ដល់ម៉ោង ៧:០០ព្រឹក និងនៅតម្លៃធម្មតាសម្រាប់ការប្រើប្រាស់អគ្គិសនីនៅពេលថ្ងៃចាប់ពីម៉ោង ៧:០០ព្រឹក ដល់ម៉ោង ៩:០០យប់។

## ៣.៤ លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនីមួយៗ

### ៣.៤.១ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

លក្ខណៈវិនិច្ឆ័យសម្រាប់សហគ្រាសអគ្គិសនីជនបទ និងគ្រួសារជនបទសម្រាប់ការអនុវត្តកម្មវិធីផ្តល់អគ្គិសនីដល់គ្រួសារក្រីក្រ មានដូចខាងក្រោម៖

#### ក. លក្ខណៈវិនិច្ឆ័យសម្រាប់សហគ្រាសអគ្គិសនីជនបទ

- មានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណមានអាណត្តិយ៉ាងតិច ៥ឆ្នាំ។
- អនុវត្តនៅតំបន់ជនបទ និងតំបន់ដែលមានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
- មានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវពីការធ្វើអាជីវកម្មអគ្គិសនី។
- យល់ព្រមប្រមូលប្រាក់បង់សងវិលស់ និងផ្ទេរចូលគណនី ម.អ.ជ. តាមពេលកំណត់។

- យល់ព្រមទទួលខុសត្រូវចំពោះគ្រួសារជនបទ ដែលពុំបង់ប្រាក់សងមក ម.អ.ជ. វិញ លើកលែងតែមានការឯកភាពពី ម.អ.ជ. ឲ្យលុបបំណុល។
- យល់ព្រមអនុវត្តៈ ១- កិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ ក្នុងការប្រើប្រាស់ឥណទានអនុគ្រោះគ្មានការប្រាក់ ២-កិច្ចសន្យាខ្ចីឥណទានអនុគ្រោះពី ម.អ.ជ. សម្រាប់តភ្ជាប់ចរន្តអគ្គិសនីដើម្បីប្រើប្រាស់ ៣-គោលការណ៍សម្រាប់អនុវត្តក្នុងការផ្តល់ឥណទានអនុគ្រោះដល់គ្រួសារក្រីក្រនៅជនបទសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

ខ. **លក្ខណៈវិនិច្ឆ័យសម្រាប់គ្រួសារជនបទ**

- គ្រួសារជនបទពុំទាន់តភ្ជាប់ចរន្តអគ្គិសនី។
- គ្រួសារជនបទមានបំណងតភ្ជាប់ចរន្តអគ្គិសនី ដែលរស់នៅក្នុងតំបន់មានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
- មានលំនៅដ្ឋានឋិតថេរ និងមានសុវត្ថិភាពសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី។
- យល់ព្រមសងរំលស់ប្រចាំខែក្នុងរយៈពេលយ៉ាងយូរ ៣៦ខែ។
- ឥណទានអនុគ្រោះគ្មានការប្រាក់ គឺមិនលើសពី ៤៨០.០០០ រៀល ក្នុង១គ្រួសារ។
- យល់ព្រមអនុវត្តៈ ១-កិច្ចសន្យាខ្ចីឥណទានអនុគ្រោះពី ម.អ.ជ. សម្រាប់តភ្ជាប់ចរន្តអគ្គិសនីដើម្បីប្រើប្រាស់ ២-គោលការណ៍សម្រាប់អនុវត្តក្នុងការផ្តល់ឥណទានអនុគ្រោះដល់គ្រួសារក្រីក្រនៅជនបទសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

### ៣.៤.២ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ

លក្ខណៈវិនិច្ឆ័យសម្រាប់អនុវត្តកម្មវិធីនេះ មានដូចខាងក្រោម៖

ក. **ទិញ-លក់ក្នុងក្របខ័ណ្ឌអនុគ្រោះដល់គ្រួសារជនបទសម្រាប់ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ អានុភាព ៨០ វ៉ាត់**

- តំបន់ជនបទដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ និងជាតំបន់ពុំមានផែនការពង្រីកខ្សែបណ្តាញទៅដល់យ៉ាងតិច ៥ឆ្នាំខាងមុខ។
- លក់ និងដំឡើងប្រព័ន្ធដល់គ្រួសារជនបទ និងវត្តអារាមនៅតំបន់ជនបទទូទាំងប្រទេសកម្ពុជា។ លក់ និងដំឡើងឲ្យក្នុង ១គ្រួសារ ១ប្រព័ន្ធ ឬវត្តអារាមមួយ ១ប្រព័ន្ធ។
- ផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ១០០ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ ដល់អ្នកទិញ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធមួយផ្នែក។
- អ្នកទិញត្រូវបង់តម្លៃសល់នៃថ្លៃប្រព័ន្ធ (តម្លៃសល់ជាថ្លៃនៅសល់បន្ទាប់ពីកាត់បន្ថយប្រាក់ឧបត្ថម្ភធន ១០០ ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ) មក ម.អ.ជ. វិញក្នុងរយៈពេល ៤ឆ្នាំ។ ចំពោះវត្តអារាម គឺតម្រូវឲ្យបង់តម្លៃសល់នៃថ្លៃប្រព័ន្ធផ្តាច់តែម្តង។ ក្រោយពេលបង់សងគ្រប់ចំនួន ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។

- អ្នកទិញអាចជ្រើសរើសជម្រើសបង់តម្លៃសល់នៃថ្លៃប្រព័ន្ធក្នុងចំណោមជម្រើសចំនួន៣ គឺៈ ជម្រើស ទី១-បង់គ្រប់ចំនួនតែម្តងនៃតម្លៃសល់ ឬជម្រើសទី២-បង់សងរំលស់តម្លៃសល់រៀងរាល់ ៦ខែម្តង រហូតដល់គ្រប់ចំនួនសម្រាប់រយៈពេល ៤ឆ្នាំ ឬជម្រើសទី៣-បង់សងរំលស់តម្លៃសល់រៀងរាល់ ២ខែម្តង រហូតដល់គ្រប់ចំនួនសម្រាប់រយៈពេល ៤ឆ្នាំ។
- ពុំតម្រូវឲ្យអ្នកទិញបង់ប្រាក់ជាមុនឡើយ។ ការបង់ប្រាក់លើកទី១ គឺត្រូវបង់នៅថ្ងៃដាក់ឲ្យដំណើរការប្រើប្រាស់ប្រព័ន្ធដែលបានដំឡើង។ ការបង់នេះ គឺត្រូវបង់ឲ្យអ្នកលក់ ឬឲ្យតំណាងស្របច្បាប់របស់អ្នកលក់។
- ការបង់រំលស់នេះ ពុំត្រូវបានអនុញ្ញាតឲ្យគិតការប្រាក់ឡើយ។
- ការដឹកជញ្ជូនពីឃ្លាំងទៅដំឡើង ការដំឡើង ការប្រមូលប្រាក់សងរំលស់ និងការថែទាំប្រព័ន្ធដល់ទីតាំង អ្នកទិញ អនុវត្តតាមរយៈក្រុមហ៊ុនក្នុងស្រុកមួយ។
- ចំណាយលើការដឹកជញ្ជូនពីឃ្លាំងទៅដំឡើង ការដំឡើង ការប្រមូលប្រាក់សងរំលស់ និងការថែទាំប្រព័ន្ធដល់ទីតាំងអ្នកទិញ ជាបន្ទុករបស់ ម.អ.ជ.។
- អ្នកទិញត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។

**ខ. ទិញ-លក់ក្នុងក្របខ័ណ្ឌអនុគ្រោះដល់គ្រួសារជនបទ សម្រាប់ផ្ទាំងដាំបាយដោយប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ អានុភាព ២០០ វ៉ាត់ និងអានុភាព ៣២៥ វ៉ាត់**

- តំបន់ជនបទដាច់ស្រយាល ដែលខ្សែបណ្តាញអគ្គិសនីមិនទាន់អាចពង្រីកទៅដល់ក្នុងរយៈពេលយូរ និងជាតំបន់ពុំមានផែនការពង្រីកខ្សែបណ្តាញទៅដល់យ៉ាងតិច ៥ឆ្នាំខាងមុខ។
- លក់ និងដំឡើងប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ ដល់គ្រួសារជនបទ និងវត្តអារាមនៅតំបន់ជនបទទូទាំងប្រទេសកម្ពុជា។ លក់ និងដំឡើងឲ្យក្នុង ១គ្រួសារ ១ប្រព័ន្ធ ឬវត្តអារាមមួយ ១ប្រព័ន្ធ។
- ផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ២០០ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ ដល់អ្នកទិញ ដើម្បីជួយកាត់បន្ថយការទូទាត់ថ្លៃទិញប្រព័ន្ធមួយផ្នែក។
- អ្នកទិញត្រូវបង់តម្លៃសល់នៃថ្លៃប្រព័ន្ធ (តម្លៃសល់ជាថ្លៃនៅសល់បន្ទាប់ពីកាត់បន្ថយប្រាក់ឧបត្ថម្ភធន ២០០ដុល្លារអាមេរិក ក្នុង១ប្រព័ន្ធ) មក ម.អ.ជ. វិញក្នុងរយៈពេល ៤ឆ្នាំ។ ចំពោះវត្តអារាម គឺតម្រូវឲ្យបង់តម្លៃសល់នៃថ្លៃប្រព័ន្ធផ្តាច់តែម្តង។ ក្រោយពេលបង់សងគ្រប់ចំនួន ប្រព័ន្ធនេះនឹងក្លាយជាកម្មសិទ្ធិរបស់អ្នកទិញ។
- អ្នកទិញអាចជ្រើសរើសជម្រើសបង់តម្លៃសល់នៃថ្លៃប្រព័ន្ធ ក្នុងចំណោមជម្រើសចំនួន ៣ គឺៈ ជម្រើស ទី១-បង់គ្រប់ចំនួនតែម្តងនៃតម្លៃសល់ ឬជម្រើសទី២-បង់សងរំលស់តម្លៃសល់រៀងរាល់ ៦ខែម្តង រហូតដល់គ្រប់ចំនួនសម្រាប់រយៈពេល ៤ឆ្នាំ ឬជម្រើសទី៣- បង់សងរំលស់តម្លៃសល់រៀងរាល់ ២ខែម្តង រហូតដល់គ្រប់ចំនួនសម្រាប់រយៈពេល ៤ឆ្នាំ។

- ពុំតម្រូវឲ្យអ្នកទិញបង់ប្រាក់ជាមុនឡើយ។ ការបង់ប្រាក់លើកទី១ គឺត្រូវបង់នៅថ្ងៃដាក់ឲ្យដំណើរការប្រើប្រាស់ប្រព័ន្ធដែលបានដំឡើង។ ការបង់នេះ គឺត្រូវបង់ឲ្យអ្នកលក់ ឬឲ្យតំណាងស្របច្បាប់របស់អ្នកលក់។
- ការបង់រំលស់នេះ ពុំត្រូវបានអនុញ្ញាតឲ្យគិតការប្រាក់ឡើយ។
- ការដឹកជញ្ជូនពីឃ្លាំងទៅដំឡើង ការដំឡើង ការប្រមូលប្រាក់សងរំលស់ និងការថែទាំប្រព័ន្ធដល់ទីតាំងអ្នកទិញ អនុវត្តតាមរយៈក្រុមហ៊ុនក្នុងស្រុកមួយ។
- ចំណាយលើការដឹកជញ្ជូនពីឃ្លាំងទៅដំឡើង ការដំឡើង ការប្រមូលប្រាក់សងរំលស់ និង ការថែទាំប្រព័ន្ធដល់ទីតាំងអ្នកទិញ ជាបន្ទុករបស់ ម.អ.ជ.។
- អ្នកទិញត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។

**គ. ប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះអានុភាព ១០ វ៉ាត់ គឺផ្តល់ជាអំណោយដល់គ្រួសារក្រីក្ររស់នៅតំបន់ដាច់ស្រយាល។**

### ៣.៤.៣ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តកម្មវិធីនេះចែកចេញជា ៣តំបន់ ផ្អែកលើដង់ស៊ីតេប្រជាពលរដ្ឋដូចខាងក្រោម៖

**តំបន់ទី១- តំបន់មានប្រជាពលរដ្ឋរស់នៅច្រើន ដែលមានប្រសិទ្ធភាពសេដ្ឋកិច្ច**

ម.អ.ជ. ផ្តល់ការធានាលើការខ្ចីឥណទានពីធនាគារក្នុងស្រុករបស់អ្នកកាន់អាជ្ញាបណ្ណអគ្គិសនីនៅតំបន់ជនបទ ដើម្បីយកទៅវិនិយោគលើការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនីឲ្យពេញដែនអាជ្ញាបណ្ណចែកចាយរបស់ខ្លួន។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី១ មានដូចខាងក្រោម៖

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវ លើការធ្វើអាជីវកម្មអគ្គិសនី។

៣. ប្រាក់កម្ចីនេះ សម្រាប់តែការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលភ្ជាប់ពីប្រព័ន្ធបណ្តាញជាតិ ឬការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញទោល។

៤. អ្នកកាន់អាជ្ញាបណ្ណអាចប្រើប្រាស់ប្រាក់កម្ចីនេះ សម្រាប់វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម (Medium Voltage - MV) និងតង់ស្យុងទាប (Low Voltage - LV) ក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងទាំងសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់ នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។

៥. អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមចុះកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយអគ្គិសនីកម្ពុជាសម្រាប់ការធានាលើការខ្ចីប្រាក់ពីធនាគារ និងជាមួយធនាគារសម្រាប់ការខ្ចីប្រាក់។

៦. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌ ដែលខ្លួនត្រូវអនុវត្តន៍ជាមួយអគ្គិសនីកម្ពុជាក្នុងកិច្ចសន្យាធានាការខ្ចីប្រាក់ពីធនាគារ រាប់ទាំងការយល់ព្រមផ្ទេរអាជ្ញាបណ្ណឲ្យអគ្គិសនីកម្ពុជា ក្នុងករណីដែលខ្លួនមិនបានសងប្រាក់តាមការកំណត់។

៧. ប្រភពថវិកា គឺពីធនាគារក្នុងស្រុក។

**តំបន់ទី២- តំបន់មានប្រជាពលរដ្ឋរស់នៅមធ្យម ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីអាចពុំចំណេញ ប្រសិនបើអ្នកផ្គត់ផ្គង់អគ្គិសនីត្រូវបង់ការប្រាក់លើដើមទុនវិនិយោគ**

ម.អ.ជ. ផ្តល់ថវិកាជួយទុនគ្មានការប្រាក់សម្រាប់វិនិយោគលើការអភិវឌ្ឍការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទដែលមានដង់ស៊ីតេប្រជាពលរដ្ឋរស់នៅមធ្យម។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី២ មានដូចខាងក្រោម៖

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវ លើការធ្វើអាជីវកម្មអគ្គិសនី។

៣. ប្រាក់កម្ចីនេះសម្រាប់តែវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទដែលផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញប៉ុណ្ណោះ។

៤. អ្នកកាន់អាជ្ញាបណ្ណអាចប្រើប្រាស់ប្រាក់កម្ចីនេះ សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីតង់ស្យុងមធ្យម (MV) និងតង់ស្យុងទាប (LV) នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន ទាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីថ្មី និងទាំងសម្រាប់ការកែលម្អហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលមានស្រាប់នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។

៥. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំប្រាក់កម្ចីនេះពី ម.អ.ជ. ដោយមានភ្ជាប់ជាមួយនូវ (i)- ផែនការអភិវឌ្ឍន៍គម្រោងលម្អិត (ii)- បញ្ជីប៉ាន់ស្មានតម្លៃសម្ភារអគ្គិសនីសម្រាប់ការអភិវឌ្ឍគម្រោង (iii)- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណ និងការកែសម្រួលពាក់ព័ន្ធទាំងអស់ (iv)- របាយការណ៍ចំណូល-ចំណាយ-បញ្ជីអចលនទ្រព្យ និងដើមទុនដែលបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (v)- លិខិតស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការផ្ទេរអាជីវកម្មអគ្គិសនីដែលមានក្នុងអាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណមិនបានសងប្រាក់ ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ និង (vi)- ឯកសារដទៃទៀតដែល ម.អ.ជ. តម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណផ្តល់សម្រាប់ការពិនិត្យលើសំណើសុំប្រាក់កម្ចីនេះ។

៦. ម.អ.ជ.ពិនិត្យពាក្យស្នើសុំ និងអនុម័តពីចំនួនទឹកប្រាក់កម្ចីសមស្រប ដែលត្រូវផ្តល់ឲ្យតាមដំណាក់កាលនីមួយៗ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ ដោយធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា។ ចំនួនទឹកប្រាក់កម្ចីនេះមិនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។ អ្នកកាន់អាជ្ញាបណ្ណត្រូវចេញដើមទុនវិនិយោគលើគម្រោងយ៉ាងតិច ២០% នៃថ្លៃដើមវិនិយោគលើគម្រោង។ ម.អ.ជ. ត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានា ក្នុងការផ្ទេរអាជ្ញាប័ណ្ណ

របស់អ្នកកាន់អាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកខ្ចីមិនបានសងប្រាក់តាមការកំណត់ដែលអ្នកកាន់អាជ្ញាបណ្ណបានឯកភាព ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ។

៧. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់កម្ចីនេះ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការផ្តល់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញនៅពេលអ្នកកាន់អាជ្ញាបណ្ណបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។

៨. ប្រាក់កម្ចីដែលបានផ្តល់ក្រោមយន្តការនេះ ពុំមានគិតការប្រាក់ឡើយ។

៩. ចំនួនទឹកប្រាក់ឲ្យខ្ចីនេះ គឺមិនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ក្នុង ១ គម្រោង។ អ្នកកាន់អាជ្ញាបណ្ណអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបាន ពេលចាំបាច់។

១០. ករណីអ្នកកាន់អាជ្ញាបណ្ណមានអាជ្ញាបណ្ណហើយ ចំនួនទឹកប្រាក់កម្ចីនេះ គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណថ្មី ចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី ដែលបានស្នើសុំរបស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១១. រយៈពេលសងប្រាក់មក ម.អ.ជ. វិញ គឺមិនលើសពី ៨ឆ្នាំ ឬមិនលើសពីអាណត្តិអាជ្ញាបណ្ណគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យខ្ចីប្រាក់។

១២. អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។

១៣. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

**តំបន់ទី៣- តំបន់មានប្រជាពលរដ្ឋរស់នៅតិចតួច ដែលការធ្វើអាជីវកម្មផ្គត់ផ្គង់អគ្គិសនីមិនចំណេញ លុះត្រាតែមានការផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែក លើដើមទុនវិនិយោគហេដ្ឋារចនា សម្ព័ន្ធអគ្គិសនី**

ម.អ.ជ. ផ្តល់ប្រាក់ឧបត្ថម្ភធនមួយផ្នែកពីលើថវិកាជួយទុនគ្មានការប្រាក់សម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។ ទឹកប្រាក់សរុបទាំងប្រាក់ឧបត្ថម្ភ និងថវិកាជួយទុនគ្មានការប្រាក់ ហៅថា "ប្រាក់ជំនួយ"។

លក្ខណៈវិនិច្ឆ័យសម្រាប់តំបន់ទី៣ មានដូចខាងក្រោម៖

១. អ្នកកាន់អាជ្ញាបណ្ណត្រូវមានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនី ដែលមានសុពលភាពចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា និងអាជ្ញាបណ្ណត្រូវមានអាណត្តិយ៉ាងតិច ៥ឆ្នាំ ចាប់ពីកាលបរិច្ឆេទខ្ចីប្រាក់។

២. អ្នកកាន់អាជ្ញាបណ្ណ ត្រូវមានការកត់ត្រារបាយការណ៍គណនេយ្យត្រឹមត្រូវលើការធ្វើអាជីវកម្មអគ្គិសនី។

៣. ប្រាក់ជំនួយនេះ សម្រាប់តែវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ដែលផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញប៉ុណ្ណោះ និងដែលត្រូវបានវាយតម្លៃដោយ ម.អ.ជ. ថាជាតំបន់អនុគ្រោះ។

៤. អ្នកកាន់អាជ្ញាបណ្ណអាចប្រើប្រាស់ប្រាក់ជំនួយនេះ សម្រាប់វិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី MV និង LV នៅក្នុងដែនអាជ្ញាបណ្ណរបស់ខ្លួន។

៥. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំប្រាក់ជំនួយពី ម.អ.ជ. ដោយមានភ្ជាប់ជាមួយនូវ (i)- ផែនការអភិវឌ្ឍគម្រោងលម្អិត (ii)- បញ្ជីប៉ាន់ស្មានតម្លៃសម្ភារអគ្គិសនីសម្រាប់ការអភិវឌ្ឍគម្រោង (iii)- ច្បាប់ចម្លងឯកសារអាជ្ញាបណ្ណ និងការកែសម្រួលពាក់ព័ន្ធទាំងអស់ (iv)- របាយការណ៍ចំណូល-ចំណាយ-បញ្ជីអចលនទ្រព្យ និងដើមទុនដែលបានវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី (v)- លិខិតស្នើសុំការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជា ក្នុងការផ្ទេរអាជីវកម្មអគ្គិសនីដែលមានក្នុងអាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណមិនបានសងប្រាក់ ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ និង (vi)- ឯកសារដទៃទៀតដែល ម.អ.ជ. តម្រូវឲ្យអ្នកកាន់អាជ្ញាបណ្ណផ្តល់ សម្រាប់ការពិនិត្យលើសំណើសុំប្រាក់ជំនួយនេះ។

៦. ម.អ.ជ. ពិនិត្យពាក្យស្នើសុំ និងអនុម័តពីចំនួនទឹកប្រាក់ជំនួយសមស្របដែលត្រូវផ្តល់ឲ្យតាមដំណាក់កាលនីមួយៗ និងចុះហត្ថលេខាលើកិច្ចសន្យាសម្រាប់ការទូទាត់ប្រាក់ និងការសងប្រាក់មកវិញ ដោយធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរអគ្គិសនីកម្ពុជា។ ចំនួនទឹកប្រាក់ជំនួយនេះ មិនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក។ អ្នកកាន់អាជ្ញាបណ្ណ ត្រូវចេញដើមទុនវិនិយោគលើគម្រោងយ៉ាងតិច ២០% នៃថ្លៃដើមវិនិយោគលើគម្រោង។ ម.អ.ជ. ត្រូវមានការឯកភាពពីអាជ្ញាធរអគ្គិសនីកម្ពុជាលើលក្ខខណ្ឌនានា ក្នុងការផ្ទេរអាជ្ញាបណ្ណរបស់អ្នកកាន់អាជ្ញាបណ្ណឲ្យទៅអគ្គិសនីកម្ពុជា ក្នុងករណីអ្នកខ្ចីមិនបានសងប្រាក់តាមការកំណត់ដែលអ្នកកាន់អាជ្ញាបណ្ណបានឯកភាព ដូចមានក្នុងកិច្ចសន្យារវាង ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ។

៧. អ្នកកាន់អាជ្ញាបណ្ណត្រូវដាក់ពាក្យស្នើសុំមក ម.អ.ជ. ដោយមានភ្ជាប់នូវរបាយការណ៍វឌ្ឍនភាពមកជាមួយ ដើម្បីស្នើសុំទូទាត់ប្រាក់ជំនួយ។ ម.អ.ជ. ផ្ទៀងផ្ទាត់វឌ្ឍនភាពការងារ និងធ្វើការផ្តល់តាមដំណាក់កាលៗ ដោយផ្អែកលើវឌ្ឍនភាពការងារ។ ម.អ.ជ. ត្រូវចេញលិខិតទទួលស្គាល់ពីចំនួនទឹកប្រាក់កម្ចីដែល ម.អ.ជ. បានទទួលមកវិញ នៅពេលអ្នកកាន់អាជ្ញាបណ្ណបានបង់រំលស់សងប្រាក់កម្ចីមក ម.អ.ជ. វិញគ្រប់ចំនួន។ ទឹកប្រាក់ដែល ម.អ.ជ. បានឧបត្ថម្ភនៅក្នុងប្រាក់ជំនួយនេះ មិនតម្រូវឲ្យសងវិញទេ។

៨. ប្រាក់កម្ចីដែលបានផ្តល់ក្រោមយន្តការនេះ ពុំមានគិតការប្រាក់ឡើយ។

៩. ចំនួនទឹកប្រាក់ជំនួយ គឺមិនលើសពី ៣០០.០០០ (បីរយពាន់) ដុល្លារអាមេរិក ក្នុង ១គម្រោង។ អ្នកកាន់អាជ្ញាបណ្ណអាចស្នើសុំអនុវត្តគម្រោងថ្មីទៀតបានពី ម.អ.ជ. ពេលចាំបាច់។

១០. ករណីអ្នកកាន់អាជ្ញាបណ្ណមានអាជ្ញាបណ្ណហើយ ចំនួនទឹកប្រាក់ឧបត្ថម្ភធន គឺមិនលើសពី ៣០% នៃតម្លៃគម្រោង និងចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលមានស្រាប់របស់អ្នកកាន់អាជ្ញាបណ្ណយោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។ ក្នុងករណីអ្នកកាន់អាជ្ញាបណ្ណថ្មី ចំនួនទឹកប្រាក់ឧបត្ថម្ភធន គឺមិនលើសពី ៣០% នៃតម្លៃគម្រោង និងចំនួនទឹកប្រាក់កម្ចី គឺមិនលើសពី ៧៥% នៃតម្លៃហេដ្ឋារចនាសម្ព័ន្ធអគ្គិសនីដែលបានស្នើសុំរបស់អ្នកកាន់អាជ្ញាបណ្ណ យោងតាមការវាយតម្លៃរបស់អាជ្ញាធរអគ្គិសនីកម្ពុជា។

១១. រយៈពេលសងប្រាក់មក ម.អ.ជ. វិញ គឺមិនលើសពី ៨ឆ្នាំ ឬ មិនលើសពីអាណត្តិអាជ្ញាបណ្ណ គិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យខ្ចីប្រាក់។
១២. អ្នកកាន់អាជ្ញាបណ្ណត្រូវយល់ព្រមអនុវត្តកិច្ចសន្យា និងឯកសារផ្លូវច្បាប់នានាជាមួយ ម.អ.ជ.។
១៣. ប្រភពថវិកា គឺពីអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់។

**៣.៤.៤ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ដល់អ្នកកាន់អាជ្ញាបណ្ណធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី**

កម្មវិធីអនុវត្តន៍សម្រាប់តែការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ដូចនេះលក្ខណៈវិនិច្ឆ័យគឺផ្អែកតាមសេចក្តីសម្រេចរបស់អាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់[4]។

**៣.៤.៥ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌**

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តន៍កម្មវិធីនេះ មានដូចខាងក្រោម៖

**ក សម្រាប់អ្នកកាន់អាជ្ញាបណ្ណ**

- មានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា។
- កម្មវិធីអនុវត្តនៅតំបន់ជនបទ និងអ្នកកាន់អាជ្ញាបណ្ណទទួលការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
- យល់ព្រមតភ្ជាប់ចរន្តកម្លាំងតែ ៥ ឬ ១០ អំពែរ ប៉ុណ្ណោះ ដល់អ្នកទទួលផល។
- យល់ព្រមផ្តល់ និងដំឡើងសម្ភារអគ្គិសនីក្នុងផ្ទះ ដូចខាងក្រោម៖
    - ប្រអប់ចែកចាយចរន្តដ៍រមានជើង DIN (ចង្កាក់ជើងឌីស្យុងទ័រ) ឬ ប្រអប់ឈើ ចំនួន ១កំប្លេរ
    - ឌីស្យុងទ័រពីរប៉ូល កម្លាំង ១០អំពែរ ចំនួន ១គ្រាប់
    - ឈ្នាប់ចរន្តសម្រាប់ស៊ិកបន្តចរន្តចេញពីព្រីភ្លើងកំលាំង ១០អំពែរ ចំនួន ១គ្រាប់
    - កន្ទុយអំពូលបំភ្លឺ ចំនួន ២គ្រាប់
    - កុងតាក់ចំនួន ២គ្រាប់
    - អំពូលបំភ្លឺ LED ចំនួន២ អានុភាពអប្បរមា ៥វ៉ាត់ ភ្លុចពន្លឺអប្បរមា ៧០ lumen ក្នុង១វ៉ាត់
    - ខ្សែចម្លងទង់ដែងស្រោម PVC មុខកាត់ ២x១.៥mm$^{២}$ ប្រវែង ២០ម៉ែត្រ ធន់សីតុណ្ហភាព ១១០$^{o}$C
    - គ្រាប់ Clip វាយកឹបខ្សែចម្លង។
- យល់ព្រមផ្តល់ និងដំឡើងខ្សែបណ្តាញសេវាកម្ម ដូចខាងក្រោម៖

[4] សេចក្តីសម្រេចស្តីពីការកំណត់នីតិវិធីសម្រាប់អនុវត្តការឧបត្ថម្ភធន ដើម្បីបន្ថយថ្លៃអគ្គិសនីរវាងអាជ្ញាធរអគ្គិសនីកម្ពុជា និងអគ្គិសនីកម្ពុជា លេខ០១១សរ.១៦អអក ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៦។

- ផ្តល់ និងដំឡើងខ្សែបណ្តាញសេវាកម្មពីចំណុចភ្ជាប់ចរន្តនាឡិកាស្ទង់លើបង្គោល មកដល់ផ្ទះ៖ ខ្សែចម្លងទង់ដែងស្រោម PVC មុខកាត់ ២x២,៥mm² ឬខ្សែចម្លងអាលុយមីញ៉ូមស្រោម PVC មុខកាត់ ២x២៥mm² (ករណីខ្សែបណ្តាញសេវាកម្ម មិនលើស ១០០ម៉ែត្រ ខ្សែចម្លងអាលុយមីញ៉ូមមុខកាត់ ២x១០mm² អាចទទួលយកបាន)។
- ដំឡើងបង្គោលឈើទ្រខ្សែចម្លងកម្ពស់អប្បបរមាពី៤ ទៅ ៥ម៉ែត្រ និងគម្លាតអតិបរមាពី ២០ ទៅ ៣០ម៉ែត្រ។ បង្គោលនេះត្រូវដាំចូលក្នុងដីឲ្យបានរឹងមាំ។

- ធានាថា សម្ភារអគ្គិសនីសម្រាប់ការតភ្ជាប់ចរន្ត ជាសម្ភារថ្មីទាំងអស់។ ការតភ្ជាប់ចរន្តអគ្គិសនី ដែលប្រើសម្ភារមិនថ្មី គឺពុំអាចទទួលប្រាក់ឧបត្ថម្ភធនឡើយ។
- យល់ព្រមអនុវត្ត៖ ១-កិច្ចសន្យារវាង ២ភាគី (ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ) ថវិកាឧបត្ថម្ភធន (ជំនួយឥតសំណង) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមគម្រោងជំនួយផ្អែកលើទិន្នផល ២-កិច្ចសន្យារវាង ៣ភាគី (ម.អ.ជ. អ្នកកាន់អាជ្ញាបណ្ណ និងអ្នកទទួលផល) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមគម្រោងជំនួយផ្អែកលើទិន្នផល និង៣-ឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

### ខ សម្រាប់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ (អ្នកទទួលផល)

- គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ដែលបានកំណត់អត្តសញ្ញាណកម្មគ្រួសារក្រីក្រពីក្រសួងផែនការ។
- គ្រួសារជនបទពុំទាន់តភ្ជាប់ចរន្តអគ្គិសនី។
- គ្រួសារជនបទមានបំណងតភ្ជាប់ចរន្តអគ្គិសនីដែលរស់នៅក្នុងតំបន់មានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
- គ្រួសារក្រីក្រត្រូវការខ្សែបណ្តាញសេវាកម្មមិនលើសពី ១៥០ម៉ែត្រ ពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកផ្ទះ។
- លំនៅដ្ឋានបិតបេរ និងមានសុវត្ថិភាពសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី។
- យល់ព្រមបង់ថ្លៃភ្ជាប់ចរន្ត និងថ្លៃប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីសម្រាប់ការតភ្ជាប់ចរន្តកម្លាំង៥ ឬ ១០អំពែរប៉ុណ្ណោះ។
- យល់ព្រមផ្តល់បង្គោលឈើទ្រខ្សែចម្លងកម្ពស់អប្បបរមាពី ៤ ទៅ ៥ម៉ែត្រ និងគម្លាតអតិបរមាពី បង្គោលមួយទៅបង្គោលមួយទៀតពី ២០ ទៅ ៣០ម៉ែត្រ។
- យល់ព្រមអនុវត្តកិច្ចសន្យារវាង ៣ភាគី (ម.អ.ជ. អ្នកកាន់អាជ្ញាបណ្ណ និងអ្នកទទួលផល) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមគម្រោងជំនួយផ្អែកលើទិន្នផល និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

## ៣.៤.៦ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភធន ៥០ដុល្លារអាមេរិក ក្នុង១គ្រួសារ

លក្ខណៈវិនិច្ឆ័យសម្រាប់ការអនុវត្តន៍កម្មវិធីនេះ មានដូចខាងក្រោម៖

### ក សម្រាប់អ្នកកាន់អាជ្ញាបណ្ណ

- មានអាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីចេញដោយអាជ្ញាធរអគ្គិសនីកម្ពុជា។
- កម្មវិធីអនុវត្តនៅតំបន់ជនបទក្នុងខេត្តពោធិ៍សាត់ បាត់ដំបង ឧត្តរមានជ័យ ខេត្តកំពង់ឆ្នាំង ខេត្តស្ទឹងត្រែង និងបណ្តាខេត្តដទៃទៀត និងអ្នកកាន់អាជ្ញាបណ្ណទទួលការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ។
- យល់ព្រមតភ្ជាប់ចរន្តកម្លាំងតែ ៥ ឬ ១០អំពែរប៉ុណ្ណោះ ដល់អ្នកទទួលផល។
- យល់ព្រមផ្តល់ និងដំឡើងសម្ភារអគ្គិសនីក្នុងផ្ទះ ដូចខាងក្រោម៖
    - ប្រអប់ចែកចាយចរន្តជំរមានជើង DIN (ចង្កាក់ជើងឌីស្យុងទ័រ) ឬ ប្រអប់ឈើ ចំនួន ១កំប្លេរ
    - ឌីស្យុងទ័រពីរប៉ូល កម្លាំង ១០អំពែរ ចំនួន ១គ្រាប់
    - ឈ្នាប់ចរន្តសម្រាប់ស៊ិកបន្តចរន្តចេញពីព្រីភ្លើង កម្លាំង ១០អំពែរ ចំនួន ១គ្រាប់
    - កន្ទុយអំពូលបំភ្លឺ ចំនួន ២គ្រាប់
    - កុងតាក់ចំនួន ២គ្រាប់
    - អំពូលបំភ្លឺ LED ចំនួន២ អានុភាពអប្បរមា ៥វ៉ាត់ ភ្លុចពន្លឺអប្បរមា ៧០ lumen ក្នុង១វ៉ាត់
    - ខ្សែចម្លងទង់ដែងស្រោម PVC មុខកាត់ ២x១,៥mm² ប្រវែង ២០ម៉ែត្រ ធន់សីតុណ្ហភាព ១១០°C
    - គ្រាប់ Clip វាយកឹបខ្សែចម្លង។
- យល់ព្រមផ្តល់ និងដំឡើងខ្សែបណ្តាញសេវាកម្ម ដូចខាងក្រោម៖
    - ផ្តល់ និងដំឡើងខ្សែបណ្តាញសេវាកម្មពីចំណុចភ្ជាប់ចរន្តនាឡិកាស្ទង់លើបង្គោលមកដល់ផ្ទះ៖ ខ្សែចម្លងទង់ដែងស្រោម PVC មុខកាត់ ២x២,៥mm² ឬខ្សែចម្លងអាលុយមីញ៉ូមស្រោម PVC មុខកាត់ ២x២៥mm² (ករណីខ្សែបណ្តាញសេវាកម្ម មិនលើស ១០០ម៉ែត្រ ខ្សែចម្លងអាលុយមីញ៉ូមមុខកាត់ ២x១០mm² អាចទទួលយកបាន)។
    - ដំឡើងបង្គោលឈើទ្រខ្សែចម្លងកម្ពស់អប្បបរមាពី៤ ទៅ ៥ម៉ែត្រ និងគម្លាតអតិបរមា ពី ២០ ទៅ ៣០ម៉ែត្រ។ បង្គោលនេះត្រូវដាំចូលក្នុងដីឲ្យបានរឹងមាំ។
- ធានាថា សម្ភារអគ្គិសនីសម្រាប់ការតភ្ជាប់ចរន្ត ជាសម្ភារថ្មីទាំងអស់។ ការតភ្ជាប់ចរន្តអគ្គិសនី ដែលប្រើសម្ភារមិនថ្មី គឺពុំអាចទទួលប្រាក់ឧបត្ថម្ភធនឡើយ។
- យល់ព្រមអនុវត្ត៖ ១-កិច្ចសន្យារវាង ២ភាគី (ម.អ.ជ. និងអ្នកកាន់អាជ្ញាបណ្ណ) ថវិកាឧបត្ថម្ភធន (ជំនួយឥតសំណង) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមគម្រោងជំនួយផ្អែកលើទិន្នផល ២-កិច្ចសន្យារវាង ៣ភាគី (ម.អ.ជ. អ្នកកាន់អាជ្ញាបណ្ណ និងអ្នកទទួលផល) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ ក្រោមគម្រោងជំនួយផ្អែកលើទិន្នផល និង៣-ឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

### ខ សម្រាប់គ្រួសារក្រីក្រ (អ្នកទទួលផល)

- គ្រួសារជនបទពុំទាន់តភ្ជាប់ចរន្តអគ្គិសនី។

- គ្រួសារជនបទមានបំណងតភ្ជាប់ចរន្តអគ្គិសនីដែលរស់នៅក្នុងតំបន់មានការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្ដាញជាតិ។
- គ្រួសារក្រីក្រត្រូវការខ្សែបណ្ដាញសេវាកម្មមិនលើសពី ១៥០ម៉ែត្រ ពីចំណុចភ្ជាប់ចរន្ត (នាឡិកាស្ទង់លើបង្គោល) មកផ្ទះ។
- លំនៅដ្ឋានបិតបេរ និងមានសុវត្ថិភាពសម្រាប់ការតភ្ជាប់ចរន្តអគ្គិសនី។
- យល់ព្រមបង់ថ្លៃភ្ជាប់ចរន្ត និងថ្លៃប្រាក់កក់ធានាថ្លៃប្រើប្រាស់អគ្គិសនីសម្រាប់ការតភ្ជាប់ចរន្តកម្លាំង៥ ឬ ១០អំពែរប៉ុណ្ណោះ។
- យល់ព្រមផ្តល់បង្គោលឈើទ្រខ្សែចម្លងកម្ពស់អប្បបរមាពី ៤ ទៅ ៥ម៉ែត្រ និងគម្លាតអតិបរមាពី បង្គោលមួយទៅបង្គោលមួយទៀតពី ២០ ទៅ ៣០ម៉ែត្រ។
- យល់ព្រមអនុវត្តកិច្ចសន្យារវាង ៣ភាគី (ម.អ.ជ. អ្នកកាន់អាជ្ញាបណ្ណ និងអ្នកទទួលផល) សម្រាប់តភ្ជាប់ចរន្តអគ្គិសនីប្រើប្រាស់ និងឯកសារចាំបាច់ពាក់ព័ន្ធនានាជាមួយ ម.អ.ជ.។

### ៣.៤.៧ លក្ខណៈវិនិច្ឆ័យសម្រាប់កម្មវិធីផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម

កម្មវិធីអនុវត្តន៍សម្រាប់តែការផ្គត់ផ្គង់អគ្គិសនីពីប្រព័ន្ធបណ្តាញជាតិ ដូចនេះលក្ខណៈវិនិច្ឆ័យ គឺផ្អែកតាមសេចក្តីសម្រេច និងនីតិវិធីសម្រាប់ផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្ម[5] របស់អគ្គិសនីកម្ពុជា និងអាជ្ញាធរអគ្គិសនីកម្ពុជាជាបន្តបន្ទាប់។

## ៣.៥ ការតែងតាំង ម.អ.ជ. ជាភ្នាក់ងារឯករាជ្យ ដើម្បីធ្វើជាសាក្សី និងវាយតម្លៃការធ្វើតេស្តរោងចក្រអគ្គិសនីដើរដោយ Solar Photovoltaic (PV)

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានទទួលការតែងតាំងជាភ្នាក់ងារឯករាជ្យ ដើម្បីធ្វើជាសាក្សី និងវាយតម្លៃការធ្វើតេស្តរោងចក្រអគ្គិសនីដើរដោយ Solar PV សរុបអានុភាព ១៥០ មេហ្គាវ៉ាត់ (MW) នៅខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់។

[5] នីតិវិធីសម្រាប់ផ្តល់ការផ្គត់ផ្គង់អគ្គិសនីសម្រាប់បូមទឹកធ្វើកសិកម្មឆ្នាំ២០១៦។

## ជំពូកទី៤
## ព័ត៌មានស្តីពីវឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធីនីមួយៗដែលបានអនុវត្ត ដោយមូលនិធិអគ្គិសនីភាវូបនីយកម្មជនបទ

ព័ត៌មានស្តីពីវឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធីនីមួយៗ ដែល ម.អ.ជ. បានអនុវត្តក្នុងឆ្នាំ២០២០ មានដូចខាងក្រោម៖

### ៤.១ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

#### ៤.១.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២០ ម.អ.ជ. ពុំបានចុះកិច្ចសន្យាសម្រាប់ការតភ្ជាប់ចរន្តថ្មីដល់គ្រួសារជនបទឡើយ ដោយសារពុំមានសេវាករដាក់ពាក្យស្នើសុំអនុវត្ត។

### ៤.២ កម្មវិធីប្រព័ន្ធថាមពលពន្លឺព្រះអាទិត្យតាមផ្ទះ (SHS)

ការអនុវត្តកម្មវិធីនេះ ម.អ.ជ. ត្រូវមានក្រុមហ៊ុនឯកជនចំនួន២ សម្រាប់ផ្តល់សេវាកម្ម រួមមាន៖ (១)- ក្រុមហ៊ុនផ្គត់ផ្គង់សម្ភារប្រព័ន្ធ SHS និង (២)- ក្រុមហ៊ុនផ្តល់សេវាកម្មដឹកជញ្ជូន ដំឡើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ SHS។

#### ៤.២.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានអនុវត្តន៍កម្មវិធីប្រព័ន្ធ SHS ចំនួន ៣ប្រភេទ រួមមាន៖ (i)- ប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ (ii)- ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ៤.០០០ ប្រព័ន្ធ (iii)- ប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្នាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ។ ប្រព័ន្ធ SHS-៨០ វ៉ាត់, ប្រព័ន្ធ SHS-២០០ វ៉ាត់ និងប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្នាំងដាំបាយអគ្គិសនី ៤លីត្រ សម្រាប់លក់ និងដំឡើងជូនគ្រួសារជនបទនៅតំបន់ដាច់ស្រយាល។

ក្នុងឆ្នាំ២០១៩ ម.អ.ជ. បានអនុវត្តន៍កម្មវិធីប្រព័ន្ធ SHS ចំនួន ៤ ប្រភេទ រួមមាន៖ (i)- ប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ (ii)- ប្រព័ន្ធ SHS-១០ វ៉ាត់ ចំនួន ២.០០០ ប្រព័ន្ធ (iii)- ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ១.៨៥០ ប្រព័ន្ធ និង (iv)- ប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្នាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ។ ប៉ុន្តែដោយសារការយឺតយ៉ាវពេលដំណើរការលទ្ធកម្ម ទើបប្រព័ន្ធទាំងនេះបានបន្តក្នុងឆ្នាំ២០២០។

- **កម្មវិធីប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-១០ វ៉ាត់ ចំនួន ២.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-២០០ វ៉ាត់, ប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្នាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ សរុបចំនួន ៩.៨៥០ ប្រព័ន្ធ (កម្មវិធីអនុវត្តន៍សម្រាប់ឆ្នាំ២០១៩)**

  កម្មវិធីប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-១០ វ៉ាត់ ចំនួន ២.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ១.៨៥០ ប្រព័ន្ធ និងប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្នាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ។ ប៉ុន្តែដោយសារការយឺតយ៉ាវពេលដំណើរការលទ្ធកម្ម ទើបប្រព័ន្ធទាំងនេះបានបន្តក្នុងឆ្នាំ២០២០។

ដើម្បីជួយសម្រួលដល់អ្នកទិញប្រព័ន្ធយកទៅប្រើប្រាស់ និងធានាថាប្រព័ន្ធដែលបានទិញ ដំណើរការជាប្រក្រតី និងដើម្បីប្រមូលថវិកាសងរំលស់ពីអ្នកទិញ អគ្គិសនីកម្ពុជាបានចុះកិច្ចសន្យាជាមួយ៖

១. ក្រុមហ៊ុន B.N.P - Power Green (Cambodia) សម្រាប់ផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូន ដំឡើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ១.៨៥០ ប្រព័ន្ធ។

២. ក្រុមហ៊ុន Lighting Engineering & Solutions សម្រាប់ផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូន ដំឡើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ និងប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងផ្ទាំងដាំបាយអគ្គិសនី ៤ លីត្រ ចំនួន ១.០០០ ប្រព័ន្ធ និងផ្គត់ផ្គង់សេវាកម្មដឹកជញ្ជូន និងដំឡើងប្រព័ន្ធ SHS-១០ វ៉ាត់ ចំនួន ២.០០០ ប្រព័ន្ធ។

ព័ត៌មានស្តីពីចំនួនប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ដែលបានដំឡើងជូនគ្រួសារជនបទ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី១** ខាងក្រោម។

**តារាងទី១៖ ព័ត៌មានស្តីពីចំនួនប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ដែលបានដំឡើងជូនគ្រួសារជនបទ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០**

| ល.រ | ខេត្ត | ចំនួនប្រព័ន្ធដែលបានលក់ និងដំឡើង |
|---|---|---|
| ប្រព័ន្ធ SHS-១០ វ៉ាត់ | | |
| ១ | បាត់ដំបង | ៦០០ |
| ២ | ពោធិ៍សាត់ | ៧៩៩ |
| ៣ | សៀមរាប | ២០០ |
| ៤ | ស្ទឹងត្រែង | ៤០០ |
| | **សរុបប្រព័ន្ធ SHS-១០ វ៉ាត់** | **១.៩៩៩** |
| ប្រព័ន្ធ SHS-៨០ វ៉ាត់ | | |
| ១ | បាត់ដំបង | ១.៤៩៥ |
| ២ | មណ្ឌលគីរី | ៤០០ |
| ៣ | ព្រះវិហារ | ៩០០ |
| ៤ | ពោធិ៍សាត់ | ៤៩៦ |
| ៥ | រតនគីរី | ៥០០ |
| ៦ | សៀមរាប | ៨០០ |
| ៧ | ស្ទឹងត្រែង | ៣៩៩ |
| | **សរុបប្រព័ន្ធ SHS-៨០ វ៉ាត់** | **៤.៩៩០** |
| ប្រព័ន្ធ SHS-២០០ វ៉ាត់ | | |
| ១ | កំពង់ឆ្នាំង | ៩៦ |
| ២ | ពោធិ៍សាត់ | ៣៨ |
| ៣ | សៀមរាប | ១១២ |
| ៤ | ស្ទឹងត្រែង | ៧៦៥ |
| ៥ | ឧត្តរមានជ័យ | ៨៣៨ |
| | **សរុបប្រព័ន្ធ SHS-២០០ វ៉ាត់** | **១.៨៤៩** |
| ប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងផ្ទាំងដាំបាយអគ្គិសនី ៤លីត្រ | | |
| ១ | ពោធិ៍សាត់ | ៧៩៨ |

| | | |
|---|---|---|
| ២ | ស្ទឹងត្រែង | ១៩៨ |
| សរុបប្រព័ន្ធ SHS-៣២៥ វ៉ាត់ | | **៩៩៦** |
| **សរុបរួម** | | **៩.៨៣៤** |

គ្រួសារជនបទបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ មានចំនួន ៩.៨៣៤ គ្រួសារ (១គ្រួសារ ១ប្រព័ន្ធ)។ តាមរបាយការណ៍ចុងក្រោយស្តីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង ១គ្រួសារ នៅជនបទ ជាមធ្យមគឺ ៤,៦ នាក់ ដូច្នេះចំនួនប្រជាពលរដ្ឋបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ គឺ ៤៥.២៣៦ នាក់។

ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី២** ខាងក្រោម។

**តារាងទី២៖ ចំនួនភូមិសរុប និងចំនួនភូមិបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ តាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០**

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិបានទទួលអគ្គិសនីប្រើប្រាស់តាមរយៈប្រព័ន្ធ SHS |
|---|---|---|---|
| ១ | បាត់ដំបង | ៨០៥ | ១១០ |
| ២ | កំពង់ឆ្នាំង | ៥៦៨ | ១១ |
| ៣ | មណ្ឌលគិរី | ៩២ | ១២ |
| ៤ | ព្រះវិហារ | ២៣២ | ២៧ |
| ៥ | ពោធិ៍សាត់ | ៥១០ | ៦២ |
| ៦ | រតនគិរី | ២៤៣ | ២៨ |
| ៧ | សៀមរាប | ៩៣០ | ២០ |
| ៨ | ស្ទឹងត្រែង | ១២៨ | ៥២ |
| ៩ | ឧត្តរមានជ័យ | ២៦០ | ៣៨ |
| **សរុប** | | **៣.៧៦៨** | **៣៦០** |

បញ្ជីឈ្មោះភូមិដែល ម.អ.ជ. បានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី១**។

ផែនទីបង្ហាញពីខេត្តបានដំឡើងប្រព័ន្ធ SHS ចំនួន ៩.៨៣៤ ប្រព័ន្ធ ក្នុងឆ្នាំ២០២០ មានបង្ហាញក្នុង **ឧបសម្ព័ន្ធទី២**។

- **កម្មវិធីប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ៤.០០០ ប្រព័ន្ធ និង ប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងថ្មាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ សរុបចំនួន ១០.០០០ ប្រព័ន្ធ (កម្មវិធីអនុវត្តន៍ សម្រាប់ឆ្នាំ២០២០)**

ក្នុងឆ្នាំ២០២០ អគ្គិសនីកម្ពុជាបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន Richgrid Technology ដែលជាក្រុមហ៊ុនទទួលបានជ័យលាភីក្នុងការដេញថ្លៃផ្គត់ផ្គង់សម្ភារប្រព័ន្ធ SHS និងបាននាំចូលសម្ភារប្រព័ន្ធ ព្រមទាំងបានប្រគល់-ទទួលជូនអគ្គិសនីកម្ពុជារួចរាល់ ក្រោមកម្មវិធីនេះ។

ក្នុងឆ្នាំ២០២០ អគ្គិសនីកម្ពុជាកំពុងដំណើរការលទ្ធកម្មជ្រើសរើសក្រុមហ៊ុនផ្តល់សេវាកម្មដឹកជញ្ជូន ដំឡើង ប្រមូលប្រាក់សងរំលស់ និងថែទាំប្រព័ន្ធ SHS-៨០ វ៉ាត់ ចំនួន ៥.០០០ ប្រព័ន្ធ, ប្រព័ន្ធ SHS-២០០ វ៉ាត់ ចំនួន ៤.០០០

ប្រព័ន្ធ និងប្រព័ន្ធ SHS-៣២៥ វ៉ាត់ និងផ្ទាំងដាំបាយអគ្គិសនី ៤លីត្រ ចំនួន ១.០០០ ប្រព័ន្ធ សរុបចំនួន ១០.០០០ ប្រព័ន្ធ។

បន្ទាប់ពីដំណើរការលទ្ធកម្មជ្រើសរើសក្រុមហ៊ុនទាំង២ខាងលើរួចរាល់ អគ្គិសនីកម្ពុជានឹងអនុវត្តន៍កម្មវិធីនេះនៅក្នុងឆ្នាំ២០២១។

### ៤.២.២ បញ្ហាប្រឈមក្នុងការអនុវត្តកម្មវិធីប្រព័ន្ធ SHS

ក្នុងការអនុវត្តកម្មវិធីនេះ ម.អ.ជ. ជួបបញ្ហាប្រឈម មានដូចខាងក្រោម៖

- អ្នកទិញស្នើសុំពន្យារពេលបង់ប្រាក់ ដោយសារពុំមានប្រាក់បង់។
- អ្នកទិញមានលទ្ធភាពបង់ ប៉ុន្តែស្ទាក់ស្ទើរមិនបង់ ដោយលើកហេតុផលថា អ្នកទិញផ្សេងទៀតមិនបង់។
- អ្នកទិញរុះរើប្រព័ន្ធខុសបច្ចេកទេសធ្វើឲ្យប្រព័ន្ធមិនដំណើរការត្រឹមត្រូវ និងគេចវេសមិនបង់ប្រាក់ ដោយលើកហេតុផលថា ប្រព័ន្ធខូចមិនដំណើរការ។
- អ្នកទិញធ្វើចំណាកស្រុក ដោយទុកឲ្យមនុស្សចាស់ជរា និង/ឬ ក្មេងតូចៗចាំផ្ទះ ពុំមានប្រាក់បង់។
- អ្នកទិញដោះប្រព័ន្ធដោយគ្មានការអនុញ្ញាត និងយកទៅកាន់ទីតាំងថ្មី ដែលជាកន្លែងពិបាកចូលទៅដល់ ដូចជាចំការ និងឡើងភ្នំ ពិបាកទាក់ទងទារប្រាក់។
- អ្នកទិញទៅធ្វើស្រែចំការ ដោយចាក់សោរផ្ទះ ហើយចោរបានលួចដោះយកប្រព័ន្ធ (អ្នកទិញខ្លះយល់ព្រមសង និងខ្លះមិនព្រមសងថ្លៃប្រព័ន្ធដែលនៅសល់)។
- អ្នកទិញគេចពីផ្ទះ នៅពេលភ្នាក់ងារប្រមូលប្រាក់ទៅដល់ ឬកំពុងធ្វើដំណើរទៅប្រមូលប្រាក់។
- អ្នកទិញយកលេសពន្យារពេលបង់ប្រាក់ថ្ងៃនេះថ្ងៃនោះ។
- ប្រព័ន្ធខូចដោយភ្លើងឆេះ និងរន្ទះបាញ់។ល។ និងអ្នកទិញបដិសេធមិនបង់ប្រាក់ដែលនៅសល់។

ដើម្បីដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើង ម.អ.ជ. បានចុះដោះស្រាយដល់ទីតាំងតាមរយៈឈរលើការពិភាក្សាគ្នាជាមិត្តភាពទៅវិញទៅមក។

ថ្វីត្បិតមានបញ្ហាប្រឈម ការអនុវត្តកម្មវិធីនេះចាត់ទុកថា គួរជាទីពេញចិត្ត។

**រូបភាពប្រព័ន្ធ SHS ដែលបានដំឡើង ក្រោមកម្មវិធី ម.អ.ជ.**












## ៤.៣ កម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

### ៤.៣.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន១០៨ ជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១០១ (អ្នកកាន់អាជ្ញាបណ្ណចំនួន៧ បានអនុវត្តកិច្ចសន្យាចំនួន២ ក្នុង១អ្នកកាន់អាជ្ញាបណ្ណ) សម្រាប់ជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ។ ក្នុងចំណោមកិច្ចសន្យាដែលបានចុះហត្ថលេខាទាំងនេះ មានកិច្ចសន្យាចំនួន៩៦ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន៨៩ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងកិច្ចសន្យាចំនួន១២ បានចុះហត្ថលេខាជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១២ ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់។

ព័ត៌មានសង្ខេបស្តីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីនេះក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៣**។

ក្នុងចំណោមកិច្ចសន្យាទាំង១០៨ ខាងលើ កិច្ចសន្យាចំនួន៩៧ បានអនុវត្តទទួលបានជោគជ័យ ១០០% ក្នុងរយៈពេលកិច្ចសន្យានៃកិច្ចសន្យា ចំណែកកិច្ចសន្យាចំនួន១១ កំពុងអនុវត្តបន្តនៅឆ្នាំ២០២១។

ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួចតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ក្រោមកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី៣** ខាងក្រោម។

**តារាងទី៣៖ ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួចតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០**

| លរ. | ខេត្ត | ប្រវែងខ្សែបណ្តាញជាប់កិច្ចសន្យា (km) | | ប្រវែងខ្សែបណ្តាញបានសាងសង់រួច (km) | |
|---|---|---|---|---|---|
| | | **តង់ស្យុងទាប (LV)** | **តង់ស្យុងមធ្យម (MV)** | **តង់ស្យុងទាប (LV)** | **តង់ស្យុងមធ្យម (MV)** |
| **I ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា** | | | | | |
| ១ | បន្ទាយមានជ័យ | ៥៦,០៥ | ២៧,៦៥ | ៥១,៤២ | ២៧,៦៥ |
| ២ | បាត់ដំបង | ១០៨,៧៧ | ៧៩,៧៧ | ១១០,៧៦ | ៨៦,២៨ |
| ៣ | កំពង់ចាម | ១៣៥,៩៣ | ៤៦,២៤ | ១៣៤,០៨ | ៤៩,០៧ |
| ៤ | កំពង់ឆ្នាំង | ៦៥,៦៨ | ៤០,៦៥ | ១១៣,០៧ | ៨៧,៥៣ |
| ៥ | កំពង់ស្ពឺ | ៣៥,៣០ | ១៦,៨៥ | ៥៦,៣០ | ២១,៩០ |
| ៦ | កំពង់ធំ | ១៥១,៩១ | ៩៥,៤៧ | ១៣៤,៤១ | ៩១,៨៧ |
| ៧ | កំពត | ១៩,៣២ | ៧៣,៥១ | ២៦,៨៩ | ៨៩,១១ |
| ៨ | កណ្តាល | ២៩,៤៣ | ៨,២៣ | ៦៦,៤៦ | ៦៨,៨២ |
| ៩ | កោះកុង | ៥៣,៨១ | ១៣,៣៥ | ៥៣,៨១ | ១៣,៣៥ |
| ១០ | ក្រចេះ | ៤០,៧៧ | - | ៥៦,៦៨ | - |
| ១១ | ព្រះវិហារ | ២៧,៧០ | ១៦,៥០ | ៦៨,៧០ | ១៤,០០ |
| ១២ | ព្រៃវែង | ៧៤,៤៧ | ១៩,៦២ | ៥៦,៩៧ | ២៣,៥២ |
| ១៣ | ពោធិ៍សាត់ | ១២៣,៩០ | ១៣,៥០ | ១៦១,៩៣ | ១៦,៤៤ |
| ១៤ | សៀមរាប | ១០៩,១៨ | ៩៧,៩០ | ១៣៥,១៣ | ១១៧,៣០ |
| ១៥ | ព្រះសីហនុ | ១,០២ | ១,៤១ | ១,០២ | ១,៤១ |
| ១៦ | ស្វាយរៀង | ៣២,៩០ | ៣៦,៧០ | ៥៦,៩១ | ៥២,៥៦ |
| ១៧ | តាកែវ | ១៥៨,០៧ | ៥៦,១៧ | ១៩០,៣៥ | ៨៨,២០ |
| ១៨ | ឧត្តរមានជ័យ | ១១,៥០ | ១២,០០ | ៣៥,១៥ | ២៥,៧០ |
| ១៩ | កែប | ១៧,៣០ | ១៨,៨៤ | ១៧,៣០ | ១៨,៨៤ |
| ២០ | ប៉ៃលិន | ៨,១០ | ១១,០០ | ៤២,៩៤ | ៦១,៨៦ |
| ២១ | ត្បូងឃ្មុំ | ២៤,៧២ | ១១,៩០ | - | - |
| **សរុប I** | | **១.២៨៥,៨៣** | **៦៩៧,២៦** | **១.៥៧០,២៨** | **៩៥៥,៤១** |
| | | **១.៩៣៤,៤៧** | | **១.១៣៨,១៩** | |

| | | | | | |
|---|---|---|---|---|---|
| **II ក្រោមថវិកាផ្តល់ដោយធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់** | | | | | |
| ១ | បន្ទាយមានជ័យ | ៩,៦០ | - | ៩,៦០ | - |
| ២ | បាត់ដំបង | ២០,១០ | ២៤,៥០ | ២០,១០ | ២៤,៥០ |
| ៣ | កំពង់ចាម | - | - | ១៩,២៧ | ៩,៤៣ |
| ៤ | កំពង់ឆ្នាំង | ២៣,២២ | ៣២,២៨ | ៣៧,៩៩ | ៤៧,៦៨ |
| ៥ | កំពង់ស្ពឺ | ៧,៨២ | ១៥,៥០ | ៣៧,១៣ | ៤៨,៩៥ |
| ៦ | កំពង់ធំ | - | - | ៦,៤៤ | ៤,៧០ |
| ៧ | កណ្តាល | - | - | ២២,០២ | ១៨,៨៥ |
| ៨ | ក្រចេះ | - | - | ៣៨,៦២ | ១,១៣ |
| ៩ | ព្រៃវែង | ២៤,១០ | ១១,២០ | ៣១,២៨ | ៧,៤៤ |
| ១០ | រតនគិរី | - | - | ២១,៣១ | ០,២៤ |
| ១១ | សៀមរាប | ៥,៥០ | - | ៤៧,៨៥ | - |
| ១២ | ព្រះសីហនុ | ៣,៧៤ | ០,៦៥ | ៣,៧៤ | ០,៦៥ |
| ១៣ | ស្ទឹងត្រែង | ១៤,៥០ | ២១,៥០ | ១៤,៥០ | ២១,៥០ |
| ១៤ | តាកែវ | ១០,១២ | - | ១០,១២ | - |
| ១៥ | កែប | - | - | ២៤,០០ | ១៦,៦០ |
| ១៦ | ត្បូងឃ្មុំ | - | - | ៦,៩០ | - |
| **សរុប II** | | **១១៨,៧០** | **១០៥,៦៣** | **៣៥០,៨៧** | **២០១,៦៧** |
| | | **២២៤,៣៣** | | **៥៥២,៥៤** | |
| **សរុប I+II** | | **២.២០៧,៤២** | | **៣.០៧៨,២៣** | |

ព័ត៌មានសង្ខេបស្តីពីប្រវែងខ្សែបណ្តាញគ្រោងសាងសង់ជាប់កិច្ចសន្យា ប្រវែងខ្សែបណ្តាញបានសាងសង់រួច និងស្ថានភាពបច្ចុប្បន្ន តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៤**។

ក្នុងឆ្នាំ២០២០ អ្នកកាន់អាជ្ញាបណ្ណបានទទួលផលដោយផ្ទាល់ក្រោមកម្មវិធីនេះ មានចំនួន១៤៥។

កម្មវិធីនេះបានផ្តល់នូវកម្លាំងរុញច្រានយ៉ាងខ្លាំងដល់សហគ្រាសអគ្គិសនីជនបទ ក្នុងការពង្រីកវិសាលភាពផ្គត់ផ្គង់អគ្គិសនីក្នុងតំបន់អាជ្ញាបណ្ណរបស់ខ្លួនឲ្យបានពេញលឿន និងគ្រួសារជនបទកាន់តែច្រើនគ្រួសារអាចទទួលបាននូវសេវាកម្មផ្គត់ផ្គង់អគ្គិសនី ដែលមានគុណភាពពីប្រព័ន្ធបណ្តាញសហគ្រាសអគ្គិសនីជនបទ។

ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនី តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី៤** ខាងក្រោម។

តារាងទី៤៖ ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ ក្រោមកម្មវិធីជួយទុនពង្រីក និងកែលម្អ ការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ក្នុងឆ្នាំ២០២០

| ល.រ | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិគ្របដណ្តប់ | |
|---|---|---|---|---|
| | | | ថវិកាផ្តល់ដោយ អគ្គិសនីកម្ពុជា | ថវិកាផ្តល់ដោយ KfW |
| ១ | បន្ទាយមានជ័យ | ៦៦១ | ៣៨ | ៩ |
| ២ | បាត់ដំបង | ៨០៥ | ៥០ | ១១ |
| ៣ | កំពង់ចាម | ៩១៦ | ១៧០ | ១៩ |
| ៤ | កំពង់ឆ្នាំង | ៥៦៨ | ៦៣ | ២៤ |
| ៥ | កំពង់ស្ពឺ | ១.៣៦២ | ៣៦ | ៣៣ |
| ៦ | កំពង់ធំ | ៧៤២ | ១០៥ | ២១ |
| ៧ | កំពត | ៤៨៨ | ៥៤ | ៦ |
| ៨ | កណ្តាល | ៩១៨ | ៧០ | ២៥ |
| ៩ | កោះកុង | ១១៧ | ២២ | - |
| ១០ | ក្រចេះ | ២៥៣ | ២៧ | ១៩ |
| ១១ | ព្រះវិហារ | ២៣២ | ៨ | - |
| ១២ | ព្រៃវែង | ១.១៣៧ | ៧៨ | ២៩ |
| ១៣ | ពោធិ៍សាត់ | ៥១០ | ៦៨ | - |
| ១៤ | រតនគិរី | ២៤៣ | - | ១៥ |
| ១៥ | សៀមរាប | ៩៣០ | ៦២ | ១៨ |
| ១៦ | ព្រះសីហនុ | ១១៥ | ៤ | ៣ |
| ១៧ | ស្ទឹងត្រែង | ១២៨ | - | ៣ |
| ១៨ | ស្វាយរៀង | ៦៩០ | ៣៣ | |
| ១៩ | តាកែវ | ១.១១៩ | ១៦០ | ៦ |
| ២០ | ឧត្តរមានជ័យ | ២៦០ | ១៧ | - |
| ២១ | កែប | ១៨ | ៥ | ៤ |
| ២២ | ប៉ៃលិន | ៧៩ | ១៤ | - |
| ២៣ | ត្បូងឃ្មុំ | ៨៥៣ | ២ | ១០ |
| **សរុប** | | **១៣.១៤៤** | **១.០៨៦** | **២៥៥** |
| **សរុបរួម** | | | **១.៣៤១** | |

**សំគាល់៖** ក្នុងចំណោម ១.៣៤១ ភូមិ មាន ១០ភូមិ បានអនុវត្តក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងថវិកាផ្តល់ដោយ ធនាគារអភិវឌ្ឍន៍អាល្លឺម៉ង់ត្រួតគ្នា។

បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្តប់ តាមខេត្តនីមួយៗ ក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់ក្រោមកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទក្នុងឆ្នាំ ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៥**។

ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជា និងធនាគារអេភិវឌ្ឍន៍អាល្លឺម៉ង់ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៦**។

### ៤.៣.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ

ដើម្បីធានាថា ការអនុវត្តកម្មវិធីជួយទុនសម្រាប់ពង្រីក និងកែលម្អការផ្គត់ផ្គង់អគ្គិសនីនៅតំបន់ជនបទ ប្រព្រឹត្តទៅត្រឹមត្រូវ និងប្រកបដោយតម្លាភាព និយោជិត ម.អ.ជ. បានចុះផ្ទៀងផ្ទាត់ការសាងសង់គ្រប់សេវាករទាំងអស់ ដែលបានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មមួយចំនួនស្តីពីការចុះផ្ទៀងផ្ទាត់ខ្សែបណ្តាញថ្មី មុនពេលសាងសង់ និងក្រោយពេលសាងសង់រួច មានបង្ហាញជូនខាងក្រោម៖

**ក្រុមហ៊ុនអគ្គិសនី ព្រៃវែង្គល (គម្រោងទី៣) កាន់អាជ្ញាបណ្ណលេខ ២៣៧អ ធ្វើសេវាកម្មអគ្គិសនី**
**នៅផ្នែកខ្លះនៃស្រុកភ្នំស្រួច និងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ**

ទីតាំងមុនពេលសាងសង់ខ្សែបណ្តាញអគ្គិសនី









ទីតាំងក្រោយពេលសាងសង់ខ្សែបណ្តាញអគ្គិសនី








## ៤.៤ កម្មវិធីផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ធ្វើអាជីវកម្មអគ្គិសនីដែលបានភ្ជាប់ប្រភពអគ្គិសនីជាមួយប្រព័ន្ធបណ្តាញជាតិ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ ក្នុងក្របខណ្ឌនៃផែនការយុទ្ធសាស្ត្របន្ថយអត្រា និងគម្លាតថ្លៃលក់អគ្គិសនីនៅក្នុងព្រះរាជាណាចក្រកម្ពុជាសម្រាប់ឆ្នាំ២០១៥ ដល់ឆ្នាំ២០២០ តាមបណ្តាខេត្ត និងរាជធានី

ក្នុងឆ្នាំ២០២០ ម.អ.ជ. ផ្តល់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីដល់អ្នកកាន់អាជ្ញាបណ្ណ ដើម្បីបន្ថយថ្លៃលក់អគ្គិសនីដល់គ្រួសារក្រីក្រនៅតំបន់ជនបទ និងអាជីវករលក់ដូរនៅផ្សារ ដូចខាងក្រោម៖

១. ចំនួន ៣២៧ តំបន់អាជ្ញាបណ្ណ ក្នុងនោះអ្នកកាន់អាជ្ញាបណ្ណចំនួន ៣២៤ តំបន់អាជ្ញាបណ្ណបានទទួលថវិកា និងចំនួន ៣ តំបន់អាជ្ញាបណ្ណ ពុំបានទទួលថវិកា ដោយសេវាករពុំស្នើសុំថវិកា និង

២. អ្នកកាន់អាជ្ញាបណ្ណធ្វើសេវាកម្មអគ្គិសនីនៅក្នុងបរិវេណផ្សារចំនួន ៦៤ តំបន់ផ្សារ ក្នុងនោះសេវាករចំនួន ៥៣ តំបន់ផ្សារ បានទទួលថវិកា និងចំនួន ១១ តំបន់ផ្សារ ពុំបានទទួលថវិកា ដោយសេវាករពុំស្នើសុំថវិកា។

ព័ត៌មានសង្ខេបស្តីពីចំនួនអតិថិជន និងបរិមាណថាមពល ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនីជូនអ្នកកាន់អាជ្ញាបណ្ណតាមខេត្តនីមួយៗ ក្នុងឆ្នាំ២០២០ សម្រាប់ខួបឆ្នាំ២០១៩ មានបង្ហាញជូនក្នុង **តារាងទី៥** និងសម្រាប់ខួបឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី៦** ខាងក្រោម។

## តារាងទី៥៖ ព័ត៌មានសង្ខេបស្ដីពីចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់វិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២០ (ខួបឆ្នាំ២០១៩)

| ល.រ | ខេត្ត/ក្រុង | ចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់វិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី | | | | | | | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| | | អតិថិជន | | | | ថាមពល (kWh) | | | | អតិថិជន | ថាមពល (kWh) |
| | | ≤១០ kWh/ខែ | ១១-៥០ kWh/ខែ | ៥១-២០០ kWh/ខែ | >២០០ kWh/ខែ | ≤១០ kWh/ខែ | ១១-៥០ kWh/ខែ | ៥១-២០០ kWh/ខែ | >២០០ kWh/ខែ | | |
| ១ | បន្ទាយមានជ័យ | ៣.៨២១ | ២៤.៥៥៣ | ៤៤.៥៥០ | ១២.៧៨៩ | ១៣២.៥៣៤ | ២.៦១៤.១៥៨ | ៣.៩០៧.៧២២ | ២.១៣៩.១៥០ | ៨៥.៧១៣ | ៨.៧៩៣.៥៦៤ |
| ២ | បាត់ដំបង | ៧.៥៦៨ | ៣២.៤០៩ | ៥១.០៤៧ | ១២.៩៣៣ | ១៣០.១៤៨ | ៣.០៨០.៥៨៣ | ៥.៨៧១.៥០៣ | ៣.៧៦១.៧៩៥ | ១០៣.៩៥៧ | ១២.៨៤៤.០២៩ |
| ៣ | កំពង់ចាម | ៩.០០១ | ៤២.១០៨ | ៨៥.៥៤៩ | ១៩.៧៧១ | ២២៨.៦២៤ | ៤.៨៩៤.៧២១ | ៧.២៨៤.៥២៣ | ៥.១៧៣.០២១ | ១៥៦.៤២៩ | ១៧.៥៨០.៨៨៩ |
| ៤ | កំពង់ឆ្នាំង | ៥.២៣៦ | ២៥.១៦៦ | ៤៦.២២៨ | ៨.៦៣៤ | ១០៧.៦៦៤ | ២.៦៤៨.៣៧៤ | ៤.១៤៥.៦៥៩ | ៣.១០៥.៤៦៧ | ៨៥.២៦៤ | ១០.០០៧.១៦៤ |
| ៥ | កំពង់ស្ពឺ | ៦.៧៥៥ | ៣៩.៤៨៩ | ៥២.៣៦៦ | ៩.៥៦៤ | ១១២.៦០៥ | ៤.៥៦២.២៣១ | ១០.៥៨៦.៧៤០ | ៦.៥៥២.០៨៣ | ១០៨.១៧៤ | ២១.៨១៣.៦៥៩ |
| ៦ | កំពង់ធំ | ៦.៨៤៣ | ២២.១០១ | ៥៣.៨៥៥ | ១៦.២៨៤ | ១៩២.១៣៧ | ៣.០៩៧.៨២៥ | ៤.០៦៣.៨៧៧ | ៣.៨៧៨.០១៨ | ៩៩.០៨៣ | ១១.២៣១.៨៥៧ |
| ៧ | កំពត | ៥.៩៥៧ | ២៩.០២៦ | ៤៨.២១១ | ១២.៧៩៦ | ១៦៥.៩៥៦ | ៣.៤៤៩.៤១១ | ៥.៤៨២.៥០៤ | ៣.៣០៦.១៦៨ | ៩៥.៩៩០ | ១២.៤០៤.០៣៩ |
| ៨ | កណ្ដាល | ២៩.៣០០ | ៩៥.៦០៧ | ៩៤.១៤៩ | ២២.៥១០ | ១៩៩.២៣២ | ៧.១៨១.៥៣៩ | ២២.៧៤០.១៨៣ | ២១.៥៦៩.៩៩៤ | ២៤១.៥៦៦ | ៥១.៦៩០.៩៤៨ |
| ៩ | កោះកុង | ១.៩០០ | ៤.៤៤៦ | ៤.១៥៧ | ១.០៩០ | ៨.៣០៣ | ២៦០.២៥៦ | ៨២៤.៦៧៨ | ១.១៥០.៥៥៣ | ១១.៥៩៣ | ២.២៤៣.៧៩០ |
| ១០ | ក្រចេះ | ១.០៩៤ | ៦.៧៥១ | ១២.៨៣៣ | ៣.៦៩៤ | ៤២.១៨៣ | ៦៨៣.១៥៣ | ១.១៧២.៨៣៤ | ៧១៤.៦៩៣ | ២៤.៣៧២ | ២.៦១២.៨៦៣ |
| ១១ | មណ្ឌលគិរី | - | - | - | ៥៣ | - | - | - | ៥.៧៣៥ | ៥៣ | ៥.៧៣៥ |
| ១២ | ភ្នំពេញ | ១៤.៣១៦ | ២.១០១ | ១.៤៧៧ | ៤.៨២៩ | ៣៤.៥១៧ | ១.២១៧.២៧១ | ១០.២៣៦.៨១០ | ១៨.១៤៤.១៤៩ | ២២.៧២៣ | ២៩.៦៣២.៧៤៧ |
| ១៣ | ព្រះវិហារ | ៣.៤០៤ | ៧.០៨០ | ១១.៤៨១ | ៣.៨០២ | ៣៨.១៣៩ | ៦៤៣.៤៧៣ | ១.៣១៥.២១៤ | ១.៦៣៥.៣៨១ | ២៥.៧៦៧ | ៣.៦៣២.២០៧ |
| ១៤ | ព្រៃវែង | ៧.២១៨ | ៤១.៥៧៥ | ៩២.២៩៨ | ១៨.៣២៥ | ២៣១.៩៤០ | ៦.៣១៩.៥២៩ | ៨.២៣៩.៥៩៤ | ៥.៧៥៥.៤៨៧ | ១៥៩.៤១៦ | ២០.៥៤៦.៥៥០ |
| ១៥ | ពោធិ៍សាត់ | ៧.៣៨៩ | ២០.៩៥៩ | ៣៩.៥៨៧ | ១០.២៤០ | ១១៥.៥៩៧ | ២.៥២៧.៥៤៣ | ៤.១៣៩.៦៥៣ | ៤.៤៩១.៥៤០ | ៧៨.១៧៥ | ១១.២៧៤.៣៣៣ |
| ១៦ | រតនគីរី | ១.៣៦៧ | ២.២៣៩ | ២.៧០៨ | ៦៩៨ | ៦.៤៨៥ | ១៥៩.២២៥ | ៤៤២.៩៨៣ | ៥៤៨.២២៩ | ៧.០១២ | ១.១៥៦.៩២២ |
| ១៧ | សៀមរាប | ៥.៣២៨ | ២២.៣៥១ | ៥១.៩៥៥ | ១៣.០៧៣ | ១៧៣.២២៣ | ៣.២៤២.៨៣១ | ៤.២៤២.២៥៥ | ៣.៤៧០.៨៨៨ | ៩២.៧០៧ | ១១.១២៩.១៩៧ |
| ១៨ | ព្រះសីហនុ | ៤.៤២២ | ១០.១២២ | ៦.៤២៤ | ៣.៥៨១ | ១០.៣៣៩ | ៤៣៧.៤០៤ | ២.០១៣.៥៦២ | ២.៨០១.២០៩ | ២៤.៥៤៩ | ៥.២៦២.៥១៤ |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ១៩ | ស្ទឹងត្រែង | ៣៦៧ | ១.២១៤ | ១.៤០៦ | ៤២៧ | ៣.៣៣៤ | ៨២.២៧៣ | ២២៨.៦៦៥ | ២២២.៦៧៩ | ៣.៤១៤ | ៥៣៦.៩៥១ |
| ២០ | ស្វាយរៀង | ៤៦៦ | ៥.៤៣២ | ១០.២៧៧ | ១.៥២១ | ១៩.៥៩១ | ៦០៥.៩៧២ | ៨៥២.២៧៣ | ២៧៣.១៧៥ | ១៧.៦៩៦ | ១.៧៥១.០១១ |
| ២១ | តាកែវ | ៩.៦៧៨ | ៥៣.៣០០ | ៧៣.៨៣៣ | ១៥.៤៤៨ | ១៣៩.៦១៦ | ៤.៥៦១.០១៩ | ៨.៨១៣.៣០០ | ៥.២០៧.០១៧ | ១៥២.២៥៩ | ១៨.៧២០.៩៥២ |
| ២២ | ឧត្តរមានជ័យ | ២.៦៩២ | ៦.៦៣០ | ១០.៧៥៩ | ៣.០៤៤ | ៣៧.៦១៨ | ៥៨៦.៥១៥ | ១.២៤៤.២២៦ | ១.៧៨៣.៧៣២ | ២៣.១២៥ | ៣.៦៥២.០៩១ |
| ២៣ | កែប | ១.៤៨៦ | ៤.៦៩៨ | ៣.១៣២ | ៦៦១ | ៤.៦៦៥ | ២១៤.៩២៤ | ៨៨៣.២៥៣ | ១.១៧២.៦០៧ | ៩.៩៧៧ | ២.២៧៥.៤៤៩ |
| ២៤ | ប៉ៃលិន | ១.០៦៣ | ២.៦២៣ | ២.៣២៧ | ៧៣៨ | ៦.១១០ | ១៧៥.០៣២ | ៥៥៥.៤០៦ | ៧២៧.៨៩២ | ៦.៧៥១ | ១.៤៦៤.៤៤០ |
| ២៥ | ត្បូងឃ្មុំ | ៥.៩០៣ | ៣០.១៨១ | ៥៤.៤១៨ | ១៣.៤៧២ | ១៤៩.៨៤២ | ៣.០៣៨.៩៧៦ | ៤.៩៩០.២៥១ | ៣.៣៧២.៩៣២ | ១០៣.៩៧៤ | ១១.៥៥២.០០១ |
| **សរុប** | | **១៤២.៥៧៤** | **៥៣២.១៦១** | **៨៥៥.០២៧** | **២០៩.៩៧៧** | **២.២៩០.៤០២** | **៥៦.២៨៤.២៣៨** | **១១៤.២៧៧.៦៦៨** | **១០០.៩៦៣.៥៩៤** | **១.៧៣៩.៧៣៩** | **២៧៣.៨១៥.៩០២** |

ក្រាភិកបង្ហាញពីបរិមាណថាមពលប្រើប្រាស់ ≤១០kWh/ខែ, ពី ១១-៥០kWh/ខែ, ពី ៥១-២០០kWh/ខែ និង > ២០០kWh/ខែ ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២០ (%) (ខួបឆ្នាំ២០១៩)



ក្រាភិកបង្ហាញពីអតិថិជនប្រើប្រាស់ ≤១០kWh/ខែ, ពី ១១-៥០kWh/ខែ, ពី ១១-៥០kWh/ខែ និង > ២០០kWh/ខែ ដែល ម.អ.ជ. បានទូទាត់
ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២០ (%) (ខួបឆ្នាំ២០១៩)



## តារាងទី៦៖ ព័ត៌មានសង្ខេបស្តីពីចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី ជូនអ្នកកាន់អាជ្ញាបណ្ណ ក្នុងឆ្នាំ២០២០ (ឆ្នាំ២០២០)

| ល.រ | ខេត្ត/ក្រុង | ចំនួនអតិថិជន និងបរិមាណថាមពលដែល ម.អ.ជ .បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវបង្គ្រប់ថ្លៃលក់អគ្គិសនី | | | | | | | | | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | អតិថិជន | | | | | ថាមពល (kWh) | | | | | | |
| | | ≤១០ kWh/ខែ | ១១-៥០ kWh/ខែ | ៥១-២០០ kWh/ខែ | >២០០ kWh/ខែ | សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទ | ≤១០ kWh/ខែ | ១១-៥០ kWh/ខែ | ៥១-២០០kWh/ខែ | >២០០ kWh/ខែ | សាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព នៅជនបទ | អតិថិជន | ថាមពល (kWh) |
| ១ | បន្ទាយមានជ័យ | ១២.៤៩៤ | ៤៦.៣១២ | ២៥.៧៩៨ | ៤.៥៩៦ | ៣៤៧ | ៤២៩.០៦៨ | ១២.២៩៣.៥៦៨ | ២៥.៤៣១.២៩៤ | ១៤.៥៩៥.៩៦៧ | ៥៩៤.០០៦ | ៨៩.៥៤៧ | ៥៣.៣៤៣.៩០៣ |
| ២ | បាត់ដំបង | ១៣.៥៩៤ | ៥៣.៩០៥ | ៣៥.៦៩៩ | ៨.០៦៥ | ៤៣៦ | ៥០៨.១១៣ | ១៤.៧៥៨.៨៧៨ | ៣៥.៤៨៦.៨៣៧ | ២៣.៦៣៣.១៥២ | ៦២៧.៨០១ | ១១១.៦៩៩ | ៧៥.០១៤.៧៨១ |
| ៣ | កំពង់ចាម | ១៩.៦៥៥ | ៨២.១០៦ | ៤៨.០៤៥ | ១០.២៣២ | ៤៧៨ | ៨២៥.៧១៤ | ២២.៣២១.៦៦៤ | ៤៤.៦៦៨.២៩១ | ៣០.៣០១.៦៣២ | ៦២១.៤២៥ | ១៦០.៥១៦ | ៩៨.៧៣៨.៧២៦ |
| ៤ | កំពង់ឆ្នាំង | ៨.៩៧០ | ៤៦.៨៦៨ | ២៧.៧០០ | ៦.២៣៣ | ២៦១ | ៤១៥.៨៣៦ | ១២.៥៩៩.៣០១ | ២៦.៤៤៤.៤០៧ | ២១.១៨៨.០០៥ | ៣៤៨.៣៩៤ | ៩០.០៣២ | ៦០.៩៩៥.៩៤៣ |
| ៥ | កំពង់ស្ពឺ | ១២.២៥២ | ៥៩.២៧៧ | ៥១.៤៨០ | ១០.៣១០ | ២៦៧ | ៤១៦.០៣១ | ១៦.០៨៥.៧៦១ | ៤៥.០០២.៦៦៦ | ៣៤.១៩៣.៩៥៤ | ៥២៨.៨៩២ | ១៣៣.៥៨៦ | ៩៦.២២៧.៣០៤ |
| ៦ | កំពង់ធំ | ១៦.៧៣៤ | ៥៨.៨៦៣ | ២៨.០៥៤ | ៨.៦៨៧ | ៤០០ | ៧១៣.១២៣ | ១៥.៤២៣.៨៦៩ | ២៥.៥៥៥.៩០៥ | ២៤.៧៨៧.៤៣៧ | ៣៨៩.២០០ | ១១២.៧៣៨ | ៦៦.៨៦៩.៥៣៤ |
| ៧ | កំពត | ១២.៧៦៧ | ៤៩.៤១៦ | ៣៣.៣៣៦ | ៧.២១៥ | ២៣០ | ៤៧៩.១៦៤ | ១៣.២៣៨.៤៣៧ | ២៩.៧៥៣.៨០៦ | ១៨.៥៨២.៣០២ | ១៧៩.៤២៧ | ១០២.៩៦៤ | ៦២.២៣៣.១៣៦ |
| ៨ | កណ្តាល | ២៣.៦១៦ | ៧៤.៥៥៩ | ៨៦.១៦៥ | ២៨.៥៩២ | ៣៥៦ | ៥៥៧.៤៤៦ | ២១.០១២.៣៦៩ | ៨២.៦៩៩.០៧៨ | ៨៤.០០៦.៩៨៩ | ៦០១.៨៧៨ | ២១៣.២៨៨ | ១៨៨.៨៧៧.៧៦០ |
| ៩ | កោះកុង | ១.២៣២ | ៤.៤៦៩ | ៥.១២២ | ២.២០១ | ៦៧ | ៣៥.៩០៨ | ១.៣១៩.៣៦២ | ៤.៨១៣.៣៥៦ | ៦.៨២២.៧៧៨ | ១២៧.៨៩៣ | ១៣.០៩១ | ១៣.១១៩.២៩៧ |
| ១០ | ក្រចេះ | ៤.២៧២ | ១៤.៨៤៧ | ៩.៧១២ | ១.៨៤១ | ១២៦ | ១៨៧.២៨៤ | ៣.៨៧៨.៧៤២ | ៩.០២៥.៨១៥ | ៥.៩៤៩.០៦៣ | ១៥៣.៦១៤ | ៣០.៧៩៨ | ១៩.១៩៤.៥១៨ |
| ១១ | មណ្ឌលគិរី | - | - | - | ៦៦ | - | - | - | - | ១៥.២៣០ | - | ៦៦ | ១៥.២៣០ |
| ១២ | ភ្នំពេញ | ៣.០៥៦ | ៦.៥៥៨ | ១៥.៥០៩ | ២៥.០១៧ | - | ៥៣.០៤៨ | ១.៧៧៣.៤៨៨ | ១៤.៨៣៦.១៧៤ | ២៧.៥០៨.៨៦៤ | ៣៥.៥១៤ | ៥០.១៤០ | ៤៤.២០៧.០៨៨ |
| ១៣ | ព្រះវិហារ | ៤.៧៤៣ | ១៥.៣៧២ | ៨.៩២២ | ៥.៧២៣ | ១៦០ | ១៦៧.៩២១ | ៣.៧៣០.៥៩២ | ៩.០១៩.៧៩៨ | ១៣.៦៥៥.៤៣៦ | ២៣៥.២៤៦ | ៣៤.៩២០ | ២៦.៨០៨.៩៩៣ |
| ១៤ | ព្រៃវែង | ២១.៤១១ | ១០១.៦១៣ | ៤៨.៧៩០ | ៨.១២២ | ៥១៦ | ៩០៧.០៧២ | ២៧.៨៤៣.៨២៥ | ៤៤.៥៤៧.២២១ | ២៣.៦០៤.៦៩០ | ១.០៣៣.៩៥១ | ១៨០.៤៥២ | ៩៧.៩៣៦.៧៥៩ |
| ១៥ | ពោធិ៍សាត់ | ៨.៤២៤ | ៤១.១៨៣ | ២៣.៩០៨ | ៧.៩១៤ | ៣១៧ | ៤០៥.៩៤០ | ១០.៩៦៨.១១៤ | ២២.២១៥.២៩១ | ២២.៦៨៤.៧៤៨ | ៥១១.៣៥២ | ៨១.៧៤៦ | ៥៦.៧៨៥.៤៤៥ |

| | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ១៦ | រតនគិរី | ៦០២ | ៣.០៩៩ | ២.៥៤១ | ១.៤៦១ | ៥៥ | ២៥.៩៨៥ | ៨៣០.៣៣០ | ២.៥៦៧.៩៩២ | ៣.៤២៩.២៥៩ | ៨៤.៤០៣ | ៧.៧៥៨ | ៦.៩៣៧.៩៦៩ |
| ១៧ | សៀមរាប | ១២.២៧២ | ៥៦.០៤៣ | ២៨.៤៤៦ | ៦.៩៨៤ | ៣៧៩ | ៥៣១.០៥៩ | ១៤.៨៣៩.៧៥០ | ២៦.៦៨២.៣២៥ | ២០.១៥៧.៤៦៤ | ៧៥២.៧៦០ | ១០៤.១២៤ | ៦២.៩៦៣.៣៥៨ |
| ១៨ | ព្រះសីហនុ | ១.៧៣៩ | ៦.១៣៣ | ១១.០១៣ | ៦.២៩៨ | ៥១ | ៤៤.៥១៦ | ១.៩៥៦.៨៤៥ | ១១.០៧៩.៦៧៧ | ១៥.២១០.២៦៧ | ៦៧.៩៥៦ | ២៥.២៣៤ | ២៨.៣៥៩.២៦១ |
| ១៩ | ស្ទឹងត្រែង | ៤៨៣ | ១.៥៤១ | ១.៤៦៨ | ៤៨៥ | ១៩ | ១៣.៨៩៤ | ៤៤៨.៣៤៨ | ១.៦១៦.២៨៣ | ១.៩៣២.៣៦៣ | ២០.៤៥២ | ៣.៩៩៦ | ៤.០៣១.៣៤០ |
| ២០ | ស្វាយរៀង | ២.៥៥៧ | ១៤.៥២៧ | ៨.៦៩០ | ៩៤៤ | ៥៧ | ១០៨.១០៧ | ៣.៨៧៨.០៧៤ | ៧.៣៧០.៨១៣ | ២.៧៤៥.៤៣៣ | ៥៩.៥៤០ | ២៦.៧៧៥ | ១៤.១៦១.៩៦៧ |
| ២១ | តាកែវ | ១៦.២៥៩ | ៧៣.៨៣៩ | ៦៤.៥០៤ | ១១.៨៧០ | ៣០៦ | ៥៧៥.០៩៤ | ២១.៩៥០.៥២៣ | ៥៩.៤៤៤.៣២៩ | ៣៥.៤២៩.៤៦៥ | ៦៥៥.៤០៩ | ១៦៦.៧៧៨ | ១១៨.០៥៤.៨២០ |
| ២២ | ឧត្តរមានជ័យ | ២.៦៨២ | ២០.១៤៦ | ៦.៣៨៥ | ២.៥៩៣ | ១២២ | ១០៧.៦៦៥ | ២.៦៦៧.៥៣៣ | ៦.៤៩៧.៦៧៥ | ១០.៥៦០.១៧០ | ៣២៦.៦០៩ | ៣១.៩២៨ | ២០.១៥៩.៦៥២ |
| ២៣ | កែប | ៧៥១ | ៣.៥៤១ | ៥.៤១៤ | ១.៧២៥ | ១៧ | ២១.២៦៣ | ១.០៤២.៧៩៥ | ៥.២៣១.២២០ | ៦.៨៨០.០១៤ | ៤៣.២៨៧ | ១១.៤៤៨ | ១៣.២១៨.៥៧៩ |
| ២៤ | ប៉ៃលិន | ៧០៤ | ២.៣៣២ | ២.៩១២ | ១.៣០៥ | ១៣ | ១៩.៧១៦ | ៦៦៥.៣០៣ | ២.៩៧៩.៦៨១ | ៤.៣៩៩.២៨៣ | ១៣.៤៤០ | ៧.២៦៦ | ៨.០៧៧.៤២៣ |
| ២៥ | ត្បូងឃ្មុំ | ១៣.៤៥៤ | ៥៧.០៨៦ | ៣៣.០៤៤ | ៧.១៧៤ | ៣៧២ | ៥៩២.៩០៤ | ១៤.៩១៥.៦៦៤ | ៣០.២១៦.១២២ | ២០.០៩៥.៨០៣ | ៤៣៥.៦០០ | ១១១.១៣០ | ៦៦.២៥៦.០៩៣ |
| **សរុប** | | **២១៤.៧២៣** | **៨៩៣.៦៣៥** | **៦១២.៦៥៧** | **១៧៥.៦៥៣** | **៥.៣៥២** | **៨.១៤១.៨៧១** | **២៤០.៤៤៣.១៣៥** | **៥៧៣.១៨៦.០៥៦** | **៤៧២.៣៦៩.៧៦៨** | **៨.៤៤៨.០៤៩** | **១.៩០២.០២០** | **១.៣០២.៥៨៨.៨៧៩** |

ក្រាភិកបង្ហាញពីបរិមាណថាមពលប្រើប្រាស់ ≤១០kWh/ខែ, ពី ១១-៥០kWh/ខែ, ពី ៥១-២០០kWh/ខែ, > ២០០kWh/ខែ និងសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាពនៅជនបទ ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២០ (%) (ឆ្នាំ២០២០)



ក្រាភិកបង្ហាញពីអតិថិជនប្រើប្រាស់ ≤១០kWh/ខែ, ពី ១១-៥០kWh/ខែ, ពី ១១-៥០kWh/ខែ, > ២០០kWh/ខែ និងសាលារៀន មន្ទីរពេទ្យ និងមណ្ឌលសុខភាព
នៅជនបទ ដែល ម.អ.ជ. បានទូទាត់ថវិកាឧបត្ថម្ភធនប៉ះប៉ូវថ្លៃលក់អគ្គិសនី ក្នុងឆ្នាំ២០២០ (%) (ខួបឆ្នាំ២០២០)



## ៤.៥ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌

### ៤.៥.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន១៥ ជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១៥ សម្រាប់ការតភ្ជាប់ចរន្តថ្មីដល់គ្រួសារជនបទមានប័ណ្ណសមធម៌។ ចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីក្រោមកិច្ចសន្យាទាំង១៥ កិច្ចសន្យានេះ មានចំនួន ២.៧៤២ គ្រួសារ និងសមិទ្ធផលនៃការតភ្ជាប់ចរន្តអគ្គិសនីក្នុងឆ្នាំ២០២០ ក្រោមកិច្ចសន្យាទាំងនេះ មានចំនួន ៣.១៤៨ គ្រួសារ។

ព័ត៌មានសង្ខេបស្តីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗក្រោមកម្មវិធីនេះក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៧**។

ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា និងចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗ ក្រោមកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី៧** ខាងក្រោម។

**តារាងទី៧៖ ព័ត៌មានស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា និងចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មីតាមខេត្តនីមួយៗក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០**

| ល.រ. | ខេត្ត | ចំនួនគ្រួសារជនបទ គ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា (គ្រួសារ) | ចំនួនគ្រួសារជនបទ បានតភ្ជាប់ចរន្តថ្មី (គ្រួសារ) |
|---|---|---|---|
| ១ | កំពង់ចាម | ២១៣ | ៥៧១ |
| ២ | កំពង់ធំ | ១.៩៦៩ | ១.៩៦៩ |
| ៣ | កណ្តាល | - | ៤៨ |
| ៤ | ក្រចេះ | ១៦០ | ២៦០ |
| ៥ | ព្រះវិហារ | ១០០ | - |
| ៦ | ពោធិ៍សាត់ | ២០ | ២០ |
| ៧ | តាកែវ | ២៨០ | ២៨០ |
| | **សរុប** | **២.៧៤២** | **៣.១៤៨** |

ព័ត៌មានសង្ខេបស្តីពីចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនីជាប់កិច្ចសន្យា ចំនួនគ្រួសារជនបទបានតភ្ជាប់ចរន្តថ្មី និងស្ថានភាពបច្ចុប្បន្ន ក្រោមកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៨**។

ក្នុងឆ្នាំ២០២០ គ្រួសារជនបទបានទទួលផលដោយផ្ទាល់ ក្រោមកម្មវិធីនេះមានចំនួន ៣.១៤៨ គ្រួសារ។ តាមរបាយការណ៍ចុងក្រោយស្តីពីអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ ចំនួនមនុស្សក្នុង១គ្រួសារនៅជនបទជាមធ្យមគឺ ៤,៦ នាក់ ដូច្នេះចំនួនប្រជាពលរដ្ឋបានទទួលផលដោយផ្ទាល់ពីកម្មវិធីនេះ គឺចំនួន ១៤.៤៨០ នាក់។

កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រនេះ ផ្តល់នូវកម្លាំងរុញច្រានយ៉ាងខ្លាំងដល់គ្រួសារនៅតំបន់ជនបទបានទទួលចរន្តអគ្គិសនីប្រើប្រាស់។

ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **តារាងទី៨** ខាងក្រោម។

**តារាងទី៨៖ ចំនួនភូមិសរុប និងចំនួនភូមិបានទទួលការផ្គត់ផ្គង់អគ្គិសនីតាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០**

| ល.រ. | ខេត្ត | ចំនួនភូមិសរុប (ជំរឿន) | ចំនួនភូមិគ្របដណ្តប់ |
|---|---|---|---|
| ១ | កំពង់ចាម | ៩១៦ | ៣៨ |
| ២ | កំពង់ធំ | ៧៤២ | ១៥៨ |
| ៣ | កំពត | ៤៨៨ | ៤ |
| ៤ | កណ្តាល | ៩១៨ | ៩ |
| ៥ | ក្រចេះ | ២៥៣ | ៣៤ |
| ៦ | ពោធិ៍សាត់ | ៥១០ | ១ |
| ៧ | តាកែវ | ១.១១៩ | ៤៩ |
| **សរុប** | | **៤.៩៤៦** | **២៩៣** |

បញ្ជីឈ្មោះភូមិតាមខេត្តនីមួយៗដែលគ្របដណ្តប់ តាមខេត្តនីមួយៗ ក្រោមកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី៩**។

ផែនទីបង្ហាញពីខេត្តដែលបានអនុវត្តកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី១០**។

### ៤.៥.២ សកម្មភាពចុះពិនិត្យការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ

ដើម្បីធានាថាការអនុវត្តកម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រមានប័ណ្ណសមធម៌ ឲ្យប្រព្រឹត្តទៅប្រកបដោយតម្លាភាព និងត្រឹមត្រូវ និយ័ោជិត ម.អ.ជ. បានចុះផ្ទៀងផ្ទាត់ការតភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទគ្រប់សេវាករទាំងអស់ដែលបានអនុវត្តកម្មវិធីនេះ។ រូបភាពសកម្មមួយចំនួនស្តីពីការចុះផ្ទៀងផ្ទាត់ការតភ្ជាប់ចរន្តអគ្គិសនីថ្មីដល់គ្រួសារជនបទ មានបង្ហាញជូនដូច ខាងក្រោម។

**លោក សឿន សុផល (គម្រោងទី៨) អាជ្ញាប័ណ្ណលេខ ៣៦៧អ ធ្វើសេវាកម្មអគ្គិសនី នៅផ្នែកខ្លះនៃស្រុកបារាយណ៍ ខេត្តកំពង់ធំ**





 

## ៤.៦ កម្មវិធីផ្តល់ចរន្តអគ្គិសនីដល់គ្រួសារក្រីក្រ ដោយផ្តល់ប្រាក់ឧបត្ថម្ភធនចំនួន ៥០ ដុល្លារអាមេរិក ក្នុង ១គ្រួសារ

### ៤.៦.១ វឌ្ឍនភាព សមិទ្ធផល និងការវិភាគពីកម្មវិធី

ក្នុងឆ្នាំ២០២០ ម.អ.ជ. បានចុះកិច្ចសន្យាចំនួន ១០ ជាមួយអ្នកកាន់អាជ្ញាបណ្ណចំនួន១០ សម្រាប់ការតភ្ជាប់ចរន្តថ្មីដល់គ្រួសារជនបទ ដោយប្រើថវិការបស់អគ្គិសនីកម្ពុជា។ ចំនួនគ្រួសារជនបទគ្រោងតភ្ជាប់ចរន្តអគ្គិសនី ក្រោមកិច្ចសន្យានេះ មានចំនួន ២.៧៩៧ គ្រួសារ និងសមិទ្ធផលនៃការតភ្ជាប់ចរន្តអគ្គិសនីក្នុងឆ្នាំ២០២០ ក្រោមកិច្ចសន្យាទាំងនេះ មានចំនួន ២.៤១៦ គ្រួសារ។

ព័ត៌មានសង្ខេបស្តីពីចុះកិច្ចសន្យាតាមខេត្តនីមួយៗក្រោមថវិកាផ្តល់ដោយអគ្គិសនីកម្ពុជាក្រោមកម្មវិធីនេះ ក្នុងឆ្នាំ២០២០ មានបង្ហាញជូនក្នុង **ឧបសម្ព័ន្ធទី១១**។

